(S-3,4
Revue Mitta sālā pāli

ឆ្នាំទី ៤ លេខ ១៤
ថ្ងៃទី ១ ខែមេសា

# ទស្សនាវដ្ដី
# មិត្តសាលាបាលី

ផ្សាយ

សាសនា, អក្សរសាស្ត្រ, ប្រវត្តិសាស្ត្រ

ចេញរាល់ថ្ងៃទី ១ នៃប្រក្រតិទិនសុរិយគតិ



ព.ស. ២៤៩៧ គ.ស. ១៩៥៤

ទីចាត់ការនៅវត្តលង្កា
សង្កាត់លេខ ៦ ក្រុងភ្នំពេញ
បណ្ណាគារ ហួត-ហៀម

សូមកែពាក្យភាន់ច្រឡំ នៅសៀវភៅលេខ ៣ ត្រង់ទំព័រទី ១០ បន្ទាត់ទី ២២ ខាងដើម ពាក្យថា មានចិត្តបាប ត្រូវកែជា មារចិត្តបាប ។
ត្រង់ទំព័រ ១៣ បន្ទាត់ទី ៥ ខុសពាក្យថា Ethnagraphie ត្រូវកែជា Ethnologie

# មាតិការឿង


| | | | |
|---|---|---|---|
| បណ្ណាធិការ | ប៊ូត-ហៀម | ........... សេចក្ដីថ្លែងការណ៍ | ទំព័រ ១ |
| " | " | ........... មានអ្វីនៅពេលចូលឆ្នាំថ្មីនេះ | " ៤ |
| ព្រះទេពសត្ថា | គឹម-ទូ | ........... អបាយមុខគឺអ្វី? | " ៩ |
| លោក | សម-ជាំង | ........... ការប្រែប្រួលវេលា មានគ្រូវទ្ធះ | " ១២ |
| មហា | មាស-ឆាន់ | ........... ដំណើរព្រះពុទ្ធសាសនានៅសហរដ្ឋអាមេរិក | " ១៤ |
| លោក | ប៉ាយ ប៊ុគា | ........... អក្សរសាស្ត្រខ្មែរក្នុងបច្ឆិមយុគ | " ១៤ |
| មហា | មាស-ឆាន់ | ....... ....ជាតិមានអ្វីជាកំឡាំង | " ១៧ |
| លោក | ហោង-យ៉ាន់ | ........... ទំនប់ ១០ បាទ | " ២១ |
| " | ប៉ាយ-ប៊ុគា | ........... ដំណើរប្រែក្រតិទិនសុរិយគតិ | " ២៣ |
| " | ប៉ាយ-ប៊ុគា | ...........ទៅស្មន៍ទន្សាយធ្វើដំណើរព័ទ្ធពិភពលោក | " ២៦ |
| " | ប៉ាយ-ប៊ុគា | ........... រូបតុក្កតាធ្វើពីទធិជាតិ | " ៣០ |
| " | តែ-ជុង | ...........រឿងជ័យប្រាជ្ញ | " ៣២ |


## ដំឡៃជាវ

| ក្នុងប្រទេស | | | ក្រៅប្រទេស | | |
|---|---|---|---|---|---|
| ៦ខែ | ១ ឆ្នាំ | ១ ក្បាល | ៦ខែ | ១ឆ្នាំ | ១ក្បាល |
| ៤៥រ៉០០ | ៩០រ៉០០ | ៩រ៉០០ | ៥៥រ៉០០ | ១០៥រ៉០០ | ១០រ៉០០ |


អ្នកទទួលជាវ

សូមផ្ញើចំពោះទៅលោកម៉ៅ-ម៉ី ធ្វើការនៅក្រសួងមហាផ្ទៃ ក្រុងភ្នំពេញ ។

**adresse :** *Monsieur* **Mao-Mey** *Ministère de l'intérieur P. Penh*


សូមអស់លោក អក័យ សាសនាប្រទេសជប៉ុន គណៈកម្មការកែប្រែពុម្ពទាន់ ។

P.K - 27
1954 - 4



# សេចក្ដីថ្លែងការណ៍អំពីអក្សរសាស្ត្រនិង សាសនារបស់សមាគមមិត្រសាលាបាលី



លោក ហួត - ហៀម បានអាននៅស្ថានវិទ្យុកម្ពុជាក្នុងថ្ងៃអង្គារ ១៣ មេសា ឆ្នាំ ១៩៥៤ ជាថ្ងៃទី ១ នៃពិធីបុណ្យចូលឆ្នាំខ្មែរ—

បងប្អូនរួមជាតិទាំងឡាយ !

គណលក្ខិកៈនៃសមាគមមិត្រសាលាបាលី មានគោលសំខាន់នៅត្រង់ការ ប្រមូលសមាជិករួមជាតិឲ្យនិយម អក្សរសាស្ត្រនិងសាសនា ។ ត្រង់ណោះហើយ ទើបខ្ញុំបាទជាតំណាងនៃសមាគម ដែលមានសិទ្ធិមកសន្ទនាក្នុងពេលនេះ បានលើកយកអក្សរសាស្ត្រនិងសាសនមកពណ៌នា ទុកជាការអំពាវនាវដល់លោកអ្នកស្ដាប់ឲ្យនិយម ។

ខ្ញុំសូមសួរនឹងឆ្លើយដោយខ្លួនឯងថាៈ ហេតុដូចម្ដេចបានជាខ្ញុំលើកយកអក្សរសាស្ត្រ និងសាសនាមកថ្លែង ? ព្រោះយល់ឃើញច្បាស់ថា អក្សរសាស្ត្រៈ

១ អក្សរសាស្ត្រទុកដូចជាទង់ជ័យជាតិ

២ អក្សរសាស្ត្រទុកដូចជាអ្នកដំណាងជាតិក្នុងអង្គការនានានៃពិភពលោក

៣ អក្សរសាស្ត្រទុកដូចជាអាករណៈ ដ៏មានជីវិតរបស់មនុស្សជាតិ ។

១– អក្សរសាស្ត្រទុកដូចជាទង់ជ័យ-ជាតិ ទង់ជ័យជាតិ មិនថាជារបស់ជាតិណា ជាជាតិណាទេ កាលបើគេក្រឡេកឃើញ គេដឹងច្បាស់ភ្លាមថាៈ ជាទង់របស់ជាតិនេះ ឬជាតិនោះ ចំណែកអក្សរក៏ដូច្នោះដែរ តែកាលណាគេក្រឡេកមើលភ្លាម គេអាចស្គាល់ភ្លែតថា ជាអក្សររបស់ជាតិនេះ ជាតិនោះមួយរំពេច ទោះបីគេពុំស្គាល់ ក៏គង់មានការសួរសាកដែរ ថាៈ នោះជាអក្សររបស់ជាតិណា ? ចុះបើយើងគ្មានអក្សរវិញ គ្មាននរណាថាយើងមានជាតិទេ, បើយ៉ាងនេះមែន សឹងមិនខុសគ្នានឹងពួកមនុស្សព្រៃប៉ុន្មានឡើយ, មនុស្សព្រៃគ្មានប្រវត្តិសាស្ត្រ គ្មានសាសនា គ្មានអ្វីចំណាំឡើយ គេសំគាល់បានត្រឹមតែឃើញរូបកាយប៉ុណ្ណោះ ។ ដូច្នេះយើងត្រូវតែមានអក្សរសាស្ត្រ និងត្រូវលើកដំកើងអក្សរសាស្ត្រយើងកុំឲ្យបាត់រូប ដូចជារក្សាទង់ជ័យជាតិឲ្យគង់វង្សកុំឲ្យបាត់ដូច្នោះដែរ ។

២ – អក្សរទុកដូចជាដំណាងជាតិ-នោះ អធិប្បាយថា មិនថាជាតិណា ជាជាតិណាទេ គ្រប់តែអង្គការទាំងអស់ ត្រូវតែមានអ្នកដំណាងទើបមានជីវិត មើលចុះប្រជាជាតិក្នុងលោក គេតែងតែ

សុំចូលក្នុងអង្គការសហប្រជាជាតិ ដើម្បីឲ្យមានដំឡៃដល់ជាតិខ្លួន ; បំណែកអក្សរសាស្ត្រយើង បើសិនជាបានបង្ហាញខ្លួនទៅក្នុងអង្គការផ្សេងៗ ហើយ ដំឡៃរបស់ជាតិយើង មិនដឹងជាមានរស្មីទៅប៉ុណ្ណាទេ; មួយទៀតអក្សរសាស្ត្រជាតិយើង កាលបើលេចមុខដល់ណា អ្នកផងគេស្គាល់ច្បាស់ថាក្នុងលោកនេះមានជាតិខ្មែរមួយដែរ ដូចជាកាល ឯកឧត្តម ទង-គិមទី កាលលុបបំបាត់ពាក្យថា “គ្មានខ្មែរនៅឥណ្ឌូចិន” ពីព្រោះតែលោកយក អក្សរ. ពង្សាវតារ ទំនៀមទំលាប់ ការរចនារបស់ជាតិ ទៅបង្ហាញគេ ទើបគេស្គាល់ខ្មែរឡើង; ដូច្នេះអក្សរសាស្ត្រ បាត់ទុកដូចជាអ្នកតំណាងជាតិ ក្នុងអង្គការផ្សេងៗ នៃពិភពលោក ។

៣ – អក្សរសាស្ត្រទុកដូចជាគ្រឿងអាភរណៈដ៏មានដំឡៃណោះ គឺ: មនុស្សណាក៏ដោយ ដែលកើតឡើងក្នុងលោកត្រូវតែមានសំលៀកបំពាក់ តែគ្មានហើយគេហៅថាមនុស្សអាក្រាត មនុស្សព្រៃ ។ល។ ជាតិដែលគ្មានអក្សរក៏ទុកដូចជាស្រាតដែរ នឹងក្លាយទៅជាជាតិឥតដំឡៃ; មនុស្សអាក្រាត គេខ្ពើមរអើមដូចម្តេចមិញ ជាតិគ្មានអក្សរក៏ដូច្នោះដែរ ។ ជាតិយើង ដែលមានអក្សរហើយ មិនប្រើទុកដូចជាអាក្រាតគ្មានខោ គ្មានអាវ នាំឲ្យជាតិគេដទៃ មើលងាយយ៉ាងខ្លាំង ។

សូមលោក-អ្នក មើលទៅប្រទេសថៃចុះគេយកតែដើងអក្សរយើងទៅប្រើផង ដោយគេមិនបណ្តោយជាតិគេឲ្យអាក្រាត, គេខ្នៃលលក ដរាបដល់អក្សរសាស្ត្រគេចំរើនដូចនានាអារ្យប្រទេសដែរ ។

កាលនៅពេលថ្មីៗនេះ មានអ្នកប្រាជ្ញម្នាក់ ធ្លាប់មានល្បីឈ្មោះខ្ទរទៅក្នុងពិភពលោក ដែលរាប់បានថា ជាអ្នកប្រាជ្ញមួយប្រាកដ លោកនោះបានមកស្រុកខ្មែរយើង, ពេលដែលលោកនោះត្រឡប់ទៅវិញ គេសួរសំដីលោកនោះពោលថា កាលចូលមកប្រទេសយើងស្មានថាជាបារាំសមួយថ្មីនៅអាស៊ីព្រោះគេឃើញតែអក្សរបារាំង គ្មានឃើញអក្សរជាតិសោះ លុះតែគេក្រឡេកឃើញ កំពូលប្រាសាទដែលជាស្នាដៃនៃសិល្បជនខ្មែរទើបគេដឹងច្បាស់ថាមិនមែនបារាំសទេ ។

អក្សរនាំជាតិឲ្យថ្កើងវិសេសណាស់ ជាតិមានដំឡៃព្រោះអក្សរ ដូច្នេះយើងត្រូវលើកដំកើងអក្សរយើងឲ្យប្រើជាផ្លូវការឲ្យបានឆាប់ ។ គ្មានខ្មែរណា ឬជនបរទេសណា ត្មះតេះដៀលមនុស្ស ដែលប្រើអក្សរសាស្ត្រខ្លួនទេ គេខ្លាចផង ព្រោះថាយើងបេះស្នេហាជាតិ ។ មនុស្សដែលបង្អាប់អក្សរសាស្ត្រខ្លួន គឺមនុស្សបង្អាប់ជាតិខ្លួន នាំជាតិឲ្យលិចលង់ នាំជាតិឲ្យអស់ដំឡៃ ។ (ដូចជាពាក្យគេថា មានសញ្ជាតិជានេះ មានអក្សរសាស្ត្រជានោះ) ដើម្បីនឹងធ្វើអក្សរសាស្ត្ររបស់យើងឲ្យមានរស្មីថ្លាល្អផុតពីការលុកលុយនៃអក្សរជនបរទេស ខ្ញុំសូមអំពាវនាវដល់បងប្អូនរួមជាតិទាំងឡាយថា សូមកុំឲ្យមានអស្មិ

មានះក្នុងការប្រើអក្សរសាស្ត្រជាតិឲ្យសោះ ត្រូវតែប្រឹងអាន សរសេរ សិក្សា ធ្វើអក្សររបស់យើង ឲ្យអណ្ដែតបានទូទៅតាមបំណង នៃរដ្ឋដែលទើបនឹងបានទទួលឯករាជ្យថ្មីៗនេះ ។

សាសនា: សាសនាដែលចាត់ទុកជាបង្គោលយ៉ាងមាំសម្រាប់ប្រទេស សមាគមយើងយកមកដំ-កើងដោយពេញលក្ខណសម្រេច; បើតាមការស្រាវជ្រាវរបស់បណ្ឌិតទាំងឡាយក្នុងពិភពលោក បានគោលទុកថា ការដែលមានវឌ្ឍនភាព ចំពោះរដ្ឋនីមួយៗគង់អាស្រ័យចក្រទាំងពីរគឺ: សាសនចក្រ និងពុទ្ធចក្រ សាសនចក្រ សម្រាប់បញ្ចេញនូវសីល-ធម៌ អារ្យធម៌និងសទ្ធិធម៌សម្រាប់ប្រជាជាតិ; អាណា-ចក្រសម្រាប់ទទួលយកនូវលោកធម៌ ក្នុងសាសនាទៅអនុវត្តន៍ ។ បើចក្រទាំងពីរនេះពុំមានដំណើរទៅស្របគ្នាទេ ប្រជាជាតិនឹងស្ថិតនៅក្នុងអវឌ្ឍនភាព (ការមិនចំរើន) ។ រដ្ឋធម្មនុញ្ញប្រទេសកម្ពុជាបានលើកព្រះពុទ្ធសាសនា ជាសាសនាប្រចាំរដ្ឋ ដោយមានព្រះមហាក្សត្រជាអគ្គសាសនូបត្ថម្ភ ប្រជាជនក្នុងរដ្ឋនិយមរាប់អានព្រះពុទ្ធសាសនា តាមប្រមុខរដ្ឋនិងតាមជំនឿរបស់ខ្លួន ជាយូរណាស់មកហើយ ។ គេចាំបានថា ព្រះពុទ្ធសាសនាប្រាកដជាបញ្ចេញសេចក្ដីសុខស្ងប់ ដល់ជនអ្នកកាន់ដោយស្មើភាគ ។ ប្រទេសកម្ពុជាយើងសព្វថ្ងៃ ពុទ្ធសាសនចក្រ និងអាណាចក្រកំពុងមានដំណើរទៅដោយប្រពៃ គួរចាត់ទុកថាជាសម័យមួយដែលប្រជាជនក្នុងរដ្ឋត្រូវយកចិត្តទុកដាក់ជាទីបំផុត និងធ្វើសាសនាកុំឲ្យរលត់ទៅតាមលំអានណាមួយ, ពិតមែនតែរដ្ឋធម្មនុញ្ញបើកសិទ្ធិឲ្យប្រជាជាតិរើសយកសាសនា ណាមួយមកកាន់តាមចិត្តស្ម័គ្រ, តែបើយើងពិនិត្យទៅតាមលំអាននៃសាមគ្គីរវាងប្រជាជាតិនិងប្រមុខរដ្ឋវិញ ក៏គួរតែយើងបរទៅតាមលំអានដែលព្រះអង្គចាប់ត្រាយទុកមក បើយើងមានសាសនាមិនស្របតាមប្រមុខរដ្ឋយើង ទុកដូចជាយើងមានមធ្យោបាយ ទទឹងនឹងប្រមុខរដ្ឋ ឬក៏គួរចាត់បានថាជាអ្នកមិនស្នេហាប្រមុខរដ្ឋ; ដើម្បីរក្សាសេចក្ដីសុខស្ងប់រៀបរយ ក្នុងប្រទេសឲ្យចំរើនឡើង យើងគួរបបួលគ្នារក្សាឲ្យខ្ជាប់នូវលទ្ធិព្រះពុទ្ធសាសនា និងការដឹកនាំនៃប្រមុខរដ្ឋ ។

ការពង្រីកសទ្ធិធម៌ឲ្យកើតមានក្នុងពិភពលោក គួរតែខំពង្រីកសីលធម៌ផ្នែកសាសនា ឲ្យមានរស្មីផ្សាយបានទូទៅ ។ ចំណែកសមាគមមិត្តសាលាបាលី បើមានកម្លាំងគ្រប់គ្រាន់ និងប្រឹងបង្កើតសាសនសិក្សាគារ (សាលាសិក្សាខាងសាសនា) និងវិជ្ជាផ្នែកសាសនា ឲ្យចម្រើនតទៅទៀត និងជួយសាសនសិក្ខាកាម (សិស្សរៀនវិជ្ជាសាសនា) ដែលគ្រប់គ្រាន់ដោយបញ្ញាឲ្យមានអាហារូបករណ៍ក្នុងការសិក្សា ក្នុងប្រទេស ឬក្រៅប្រទេស ។

សាសនានោះហើយ ដែលជាពន្លឺនៃសន្តិភាព; ប្រទេសសេរីទាំងឡាយតែងត្រូវការណាស់គ្រឹះសន្តិ

ភាព; អ្នកប្រាជ្ញលោកបានស្វែងរកជាយូរហើយតាមយោបល់ផ្សេងគ្នា មានការបង្កើតអាវុធពិសេសជាដើម ដើម្បីសន្តិភាព ; បើតាមទំនាយអ្នកសាសនាថាការចង់បានសន្តិភាព ដោយយកអាវុធពិសេសទៅប្រព្រឹត្ត ជាពុំបានដោយដាច់ខាត ។ បើចង់បានសន្តិភាពសម្រាប់លោក ឬសម្រាប់រដ្ឋនីមួយ ៗ ក៏គួរតែអប់រំទៅតាមគោលនៃលទ្ធិពុទ្ធសាសនា កាលបើមានបំណងស្របគ្នាទៅតាមលទ្ធិនេះហើយ លទ្ធិនេះនឹងត្រាយផ្លូវមួយដ៏ប្រពៃ សម្រាប់ឲ្យអ្នកដើរទៅរកសន្តិភាព,យើងនឹងអាចដឹងច្បាស់ថា ព្រះពុទ្ធសាសនាជារឿងនៃសន្តិភាព ពិតប្រាកដមែន

ទីបំផុតនៃសេចក្តីបរិយាយអំពីអក្សរសាស្ត្រនឹងសាសនាខ្ញុំសូមបញ្ជាក់ថា បងប្អូនរួមជាតិទាំងឡាយមុននឹងប្រកបកិច្ចអ្វីមួយគួរនឹកកុំភ្លេចថា អក្សរសាស្ត្រជាតួទង់ជាតិ សាសនាជាដងនៃទង់ជ័យជាតិ ។

នៅទីបញ្ចប់នេះ សមាគមមិត្តសាលាបាលីសូមបួងសួងដល់គុណព្រះរតនត្រ័យ— ទេវបុត្រក្នុងឆ្នាំថ្មីនេះ ទេវតារក្សាស្វេតច្ឆត្រ នឹងចំពោះវត្ថុស័ក្តិសិទ្ធិក្នុងលោក សូមព្រះមហាវីរក្សត្រ អគ្គមហាបុរសរតន៍ ព្រះចៅប្រទេសកម្ពុជាសម្តេចព្រះវរាជបិតាសម្តេចព្រះវររាជនីនាថព្រមទាំងព្រះរាជវង្សានុវង្សសូមឲ្យទ្រង់គង់ជាសុខក្នុងសិរីរាជសម្បត្តិ នឹងឲ្យមានជ័យជំនះ តាមព្រះរាជបំណង សូមឲ្យឧបសគ្គបន្តិចបន្តួច ដែលចូលមកកពាំងសភាពនៃឯករាជ្យជាជំបូងនេះវិនាសអន្តរធានទៅ ។

សូមប្រគេនពរចំពោះ សម្តេចព្រះមហាសុធម្មាធិបតី, សម្តេចព្រះមហាសុមេធាធិបតី, សម្តេចព្រះធម្មលិខិតឧត្តមប្រឹក្សា សូមជូនពរចំពោះរាជរដ្ឋាភិបាល សូមសម្តេចទ្រង់ ឯកឧត្តម គង់ ឋិត នៅជាសុខនឹងប្រាសចាកឧបទវន្តរាយគ្រប់យ៉ាង ប្រជាជនក្នុងប្រទេសទូទៅ ក៏សូមឲ្យបានសេចក្តីសុខស្ងប់រៀបរយចាប់តាំងពីឆ្នាំថ្មី ព.ស.២៤៩៧នេះតទៅ ៖

ជយោ ! ព្រះពុទ្ធសាសនា អក្សរសាស្ត្រ

ព្រះមហាក្សត្រ

---

## មានអ្វីនៅពេលចូលឆ្នាំថ្មីនេះ?...

ឆ្នាំមមីឆស័កជាលក្ខណ៍តោគាង្គា
នាងទេពប្រសើររៀបដំណើរចុះមក
លើកជោគភាសីសិរីកម្ពុជា ។
ខ្ញុំសូមគាល់បង្គំផ្ទាល់ព្រះនាងទេព
សូមសេពសិរីក្តីសុខដល់រដ្ឋ
សូមជួយថែម្រែងម្រង់ជាតិខេមរា
ឲ្យចេះស្នេហាសាសនាមហាក្សត្រ ។
សូមជួយឲ្យចេះរិះរកសុខមគ្គ
នឹងចេះស្អាកដំណើរធ្វើឲ្យវិបត្តិ
នឹងស្គាល់ដំណើរឯករាជ្យដោយមធ្យ័ត
នឹងបំបាត់ការវង្វេងធម៌សាមគ្គី ។
ឲ្យមានភក្តីមេត្រីស្នេហាពិត



ចំពោះមិត្តរួមសញ្ជាតិរួមដី
ដើរឲ្យត្រង់តាមផ្លូវដែលព្រះភូមិ
ទ្រង់ត្រាទ់តាមវិធីខ្មែរអគ្គ ។
ឯកភាពមានពន្លឺកាន់តែថ្លា
ជនស្នេហាត្រូវរក្សាកុំវីវរ,
តាមរបៀបខ្មែរបូរាណឲ្យបានល្អ
ពន្លឺសរវិសេសបែសជាជោគជ័យ ។
សូមឲ្យស្គាល់គោលគាប់ភ័ពកម្ពុជៈ
ជាតិជាអគ្គសាសនាមហាក្សត្រថ្លៃ
កុំឲ្យរលប់តាកកតពលោកសេរី
ធ្វើដើម្បីជ័យជំនះកម្ពុជា ។
ខ្ញុំសូមអង្វរទេពព្រក្សអារក្សលោក
នៅគគោកពាសពេញលើពសុធា
សូមអាណិតមិត្តខ្សត់ខ្សោយវង់វេទនា
សូមមើលគ្នាតាមមេត្តាចិត្តកុសល ។
ទុទេព្តារក្សាផែនចក្រវាឡ
នាយកិបាលលើអស់ទេព្តាសាកល
សូមបាត់សុទេពវៀបកពមណ្ឌល
កុំឲ្យវល់ពីការឈ្លោះដណ្តើមគ្នា ។
ឲ្យមានគំនិតប្រាសចាកការលោភលន់
ដណ្តើមធនពីជនប្រាសចាកគេជា

ដណ្តើមដីដោយក្តីលោភហួសភាសនា
គ្មានករុណាដល់រដ្ឋតូចស្លូតទៀងត្រង់ ។
សូមឈប់ឈ្លោះឈប់ប្រកែកដណ្តើមឈ្នះ
សូមតាមព្រះជាគ្រូនៃសមណៈវង្ស
ទ្រង់បានប្រដៅសត្វលោកឲ្យទ្រទ្រង់
ធ្វើតាមអគ្គសទ្ធម៌ល្អប្រពៃ ។
ព្រះពុទ្ធសំដែងឲ្យសត្វប្រឹងប្រាសចាក
ធម៌ជាភាគដែលនាំឲ្យកើតចង្រៃ
គឺការទឹងវង្វេងលោភហួសវិស័យ
ទឹងកើតភ័យក្នុងផ្ទៃនៃលោកខាងក្រោម ។
ហេតុនេះបានជាខ្ញុំសូមចូលមកជិត
ចូលសណ្ឋិតសូមចិត្តទេពឲ្យល្ហួងលោម
ចិត្តជនសាកលឲ្យយល់ការទ្រុឌទ្រោម
អនុលោមពុទ្ធដីកាព្រះម្ចាស់វិញ ។
ទីបំផុតសូមថ្វាយព្រះពរតេជ
ជាអនេកអនន្តមានដំពេញលេញ

ដល់មហាក្សត្រដែលទ្រង់បានបំពេញ
ទ្រង់បណ្ដេញភ័យអន្តរាយចាកនគរ ។
សូមទេវៈទេពជួយផ្ដល់ផលដ៏ស័ក្ដិសិទ្ធ
សត្រូវជិតឲ្យវិនាសទាំងជំហរ
ឲ្យពលរដ្ឋក្សេមចាកភ័យហើយត្រេកអរ
មានអំណរដោយជ័យជោគគ្រប់ៗ កាល ។
សូមរស្មីសិរីរដ្ឋកម្ពុជ:
ក្ដីស្រឡះស្មើព្រះសូរ្យចិតទីពល
គ្មានឧកាមកបាំងបិទពន្លឺព្រាល
វិសេសសាលរុងរោចន៍ដូចជាន់ជយវន្ត ។
សូមជួយផ្សាយអំណាចសាសនពុទ្ធ
ឲ្យមុះមុតលើផ្ទៃលោកយ៉ាងសំខាន់
ឲ្យស្គាល់អត្ថជាប្រយោជន៍ គួរចាប់កាន់
នឹងបានបាន់គាថដំណើរសន្តិភាព ។

សួស្ដីទេពធាំមមី

* *
*

## មុននឹងផ្លាស់គួរលាគ្នាសិន

ពស់ - នែមិត្ត! ខ្ញុំលាមិត្តឯងសិនហើយណា!

សេះ - យី! ទៅឯណាភ្លាម បើខ្ញុំពុំទាន់បានជប់លៀងឯងផង ។

ពស់ – ជប់លៀងអី?

សេះ– មាក់តែល - ភេម -

ពស់ – ទេ! ខ្ញុំពុំចេះទេ បើទឹកត្នោតជូរទើប-ខ្ញុំចេះ ។

សេះ– គេថាផឹកស្រាបារាំង ឯងទៅជាថាផឹកទឹកត្នោតជូ ដឹងទឹកត្នោតជូជាថ្នាំពុលទេ ។

ពស់ – បើទឹកត្នោតជូពុលស្រាបារាំងក៏ពុល-ដូចជាគ្នា ព្រោះវត្ថុនេះចាត់ចូលក្នុងសុរានឹងមេរ័យទាំងអស់; ក្រោយឈប់និយាយពីរឿងផឹកស៊ីទៅគ្មានបានការអីទេ! នែបងសេះ ខ្ញុំមុននឹងឈានជើងចេញចាករដ្ឋកម្ពុជានេះ ខ្ញុំដូចជាមិនអស់ចិត្តសោះ ព្រោះប្រទេសនេះកំពុងតែតាំងនៅក្នុងភយន្តរាយជាខ្លាំងនាំ-ឲ្យខ្ញុំកើតក្នុងចិត្តឥតឧបមា មុននឹងខ្ញុំនិយាយរឿងនេះប្រាប់ឯង ខ្ញុំស្ទើរតែស្រែកយំបន្អើលទេវលោកម្ដង បើសិនជាខ្ញុំយំទៅកុំឲ្យគេថាខ្ញុំឆ្កួត; ហេតុនេះមិត្តគួរយល់ដល់ខ្ញុំផង ខ្ញុំសូមប្រាប់មិត្តឲ្យច្បាស់ដូចតទៅ ។

មិត្តមុននឹងអ្នកចូលកាន់មុខការថ្មី គួរអ្នកចាំបានថាប្រទេសកម្ពុជាជារដ្ឋមួយតូច មានប្រជាជនក៏តិច ហើយសុទ្ធតែជាមនុស្ស អ្នកស្លូតត្រង់ ពលរដ្ឋគោរពព្រះពុទ្ធសាសនាស្មើជីវិតរបស់ខ្លួន មិនដែលមានការបៀតបៀនឬឈ្នានីសដល់ជនណាមួយ ។ ចិត្តតាំងនៅក្នុងសប្បុរសធម៌ស្មើរគ្រប់គ្នា មិនដែលរាតអំណាចចូលទៅកាន់ព្រំដែនរដ្ឋណាមួយ ដោយចិត្តដ៏លោភលន់ឡើយ ប្រឹងតែរក្សាសេចក្ដីសុខសប្បរៀបរយក្នុងប្រទេសប៉ុណ្ណោះ ។

| មេសា អាព្រិល | ផល្គុន ចែត្រ | ឧសភា មេ | ចេត្រ ពិសាខ | មិថុនា យូអ៊ុំង | ជេស្ឋ | កក្កដា ស៊ុយេត | អាសាឍ ស្រាពណ៍ | សីហា អ៊ូត | ស្រាពណ៍ ភទ្របទ | កញ្ញា សេតតម្ប៍ | ភទ្របទ អស្សុជ |
|---|---|---|---|---|---|---|---|---|---|---|---|
| ១ ព្រ. | ១៤ រ. | ១ ស. | ១៤ ខ.ដ. | ១ អ. | ១ ក. | ១ ព្រ. | ១ ក. | ១ អា. | ២ ក. | ១ ពុ. | ៤ ក. |
| ២ សុ. | ១៥ ខ.ដ. | ២ អា. | ១ ក. | ២ ពុ. | ២ | ២ សុ. | ២ | ២ ច. | ៣ | ២ ព្រ. | ៥ |
| ៣ ស. | ១ ក. | ៣ ច. | ២ | ៣ ព្រ. | ៣ | ៣ ស. | ៣ | ៣ អ. | ៤ | ៣ សុ. | ៦ |
| ៤ អា. | ២ | ៤ អ. | ៣ | ៤ សុ. | ៤ | ៤ អា. | ៤ | ៤ ពុ. | ៥ | ៤ ស. | ៧ |
| ៥ ច. | ៣ | ៥ ពុ. | ៤ | ៥ ស. | ៥ | ៥ ច. | ៥ | ៥ ព្រ. | ៦ | ៥ អា. | ៨ |
| ៦ អ. | ៤ | ៦ ព្រ. | ៥ | ៦ អា. | ៦ | ៦ អ. | ៦ | ៦ សុ. | ៧ | ៦ ច. | ៩ |
| ៧ ពុ. | ៥ | ៧ សុ. | ៦ | ៧ ច. | ៧ | ៧ ពុ. | ៧ | ៧ ស. | ៨ | ៧ អ. | ១០ |
| ៨ ព្រ. | ៦ | ៨ ស. | ៧ | ៨ អ. | ៨ | ៨ ព្រ. | ៨ | ៨ អា. | ៩ | ៨ ពុ. | ១១ |
| ៩ សុ. | ៧ | ៩ អា. | ៨ | ៩ ពុ. | ៩ | ៩ សុ. | ៩ | ៩ ច. | ១០ | ៩ ព្រ. | ១២ |
| ១០ ស. | ៨ | ១០ ច. | ៩ | ១០ ព្រ. | ១០ | ១០ ស. | ១០ | ១០ អ. | ១១ | ១០ សុ. | ១៣ |
| ១១ អា. | ៩ | ១១ អ. | ១០ | ១១ សុ. | ១១ | ១១ អា. | ១១ | ១១ ពុ. | ១២ | ១១ ស. | ១៤ កោរ |
| ១២ ច. | ១០ | ១២ ពុ. | ១១ | ១២ ស. | ១២ | ១២ ច. | ១២ | ១២ ព្រ. | ១៣ | ១២ អា. | ១៥ បុណ៌ |
| ១៣ អ. | ១១ មមី | ១៣ ព្រ. | ១២ | ១៣ អា. | ១៣ | ១៣ អ. | ១៣ | ១៣ សុ. | ១៤ កោរ | ១៣ ច. | ១ រ. |
| ១៤ ពុ. | ១២ | ១៤ សុ. | ១៣ | ១៤ ច. | ១៤ កោរ | ១៤ ពុ. | ១៤ កោរ | ១៤ ស. | ១៥ បុណ៌ | ១៤ អ. | ២ |
| ១៥ ព្រ. | ១៣ ឮ.ស | ១៥ ស. | ១៤ កោរ | ១៥ អ. | ១៥ បុណ៌ | ១៥ ព្រ. | ១៥ បុណ៌ | ១៥ អា. | ១ រ. | ១៥ ពុ. | ៣ |
| ១៦ សុ. | ១៤ កោរ | ១៦ អា. | ១៥ បុណ៌ | ១៦ ពុ. | ១ រ. | ១៦ សុ. | ១ រ.ច.រ. | ១៦ ច. | ២ | ១៦ ព្រ. | ៤ |
| ១៧ ស. | ១៥ បុណ៌ | ១៧ ច. | ១ រ. | ១៧ ព្រ. | ២ | ១៧ ស. | ២ | ១៧ អ. | ៣ | ១៧ សុ. | ៥ |
| ១៨ អា. | ១ រ. | ១៨ អ. | ២ | ១៨ សុ. | ៣ | ១៨ អា. | ៣ | ១៨ ពុ. | ៤ | ១៨ ស. | ៦ |
| ១៩ ច. | ២ | ១៩ ពុ. | ៣ | ១៩ ស. | ៤ | ១៩ ច. | ៤ | ១៩ ព្រ. | ៥ | ១៩ អា. | ៧ |
| ២០ អ. | ៣ | ២០ ព្រ. | ៤ | ២០ អា. | ៥ | ២០ អ. | ៥ | ២០ សុ. | ៦ | ២០ ច. | ៨ |
| ២១ ពុ. | ៤ | ២១ សុ. | ៥ | ២១ ច. | ៦ | ២១ ពុ. | ៦ | ២១ ស. | ៧ | ២១ អ. | ៩ |
| ២២ ព្រ. | ៥ | ២២ ស. | ៦ | ២២ អ. | ៧ | ២២ ព្រ. | ៧ | ២២ អា. | ៨ | ២២ ពុ. | ១០ |
| ២៣ សុ. | ៦ | ២៣ អា. | ៧ | ២៣ ពុ. | ៨ | ២៣ សុ. | ៨ | ២៣ ច. | ៩ | ២៣ ព្រ. | ១១ |
| ២៤ ស. | ៧ | ២៤ ច. | ៨ | ២៤ ព្រ. | ៩ | ២៤ ស. | ៩ | ២៤ អ. | ១០ | ២៤ សុ. | ១២ |
| ២៥ អា. | ៨ | ២៥ អ. | ៩ | ២៥ សុ. | ១០ | ២៥ អា. | ១០ | ២៥ ពុ. | ១១ | ២៥ ស. | ១៣ |
| ២៦ ច. | ៩ | ២៦ ពុ. | ១០ | ២៦ ស. | ១១ | ២៦ ច. | ១១ | ២៦ ព្រ. | ១២ | ២៦ អា. | ១៤ កោរ |
| ២៧ អ. | ១០ | ២៧ ព្រ. | ១១ | ២៧ អា. | ១២ | ២៧ អ. | ១២ | ២៧ សុ. | ១៣ កោរ | ២៧ ច. | ១៥ ខ.ដ. |
| ២៨ ពុ. | ១១ | ២៨ សុ. | ១២ | ២៨ ច. | ១៣ | ២៨ ពុ. | ១៣ | ២៨ ស. | ១៤ ខ.ដ. | ២៨ អ. | ១ ក. |
| ២៩ ព្រ. | ១២ | ២៩ ស. | ១៣ | ២៩ អ. | ១៤ កោរ | ២៩ ព្រ. | ១៤ កោរ | ២៩ អា. | ១ ក. | ២៩ ពុ. | ២ |
| ៣០ សុ. | ១៣ កោរ | ៣០ អា. | ១៤ កោរ | ៣០ ពុ. | ១៥ ខ.ដ. | ៣០ សុ. | ១៥ ខ.ដ. | ៣០ ច. | ២ | ៣០ ព្រ. | ៣ |
| | | ៣១ ច. | ១៥ ខ.ដ. | | | ៣១ ស. | ១ ក. | ៣១ អ. | ៣ | | |

| តុលា អុកតូប្រ៍ | | អស្សុជ កត្តិក | | វិច្ឆិកា ណូវ៉ែមប្រ៍ | | កត្តិក មិគសិរ | | ធ្នូ ដេសំប្រ៍ | | មិគសិរ បុស្ស | | មករា យ៉ាំងវីយេរ | | បុស្ស មាឃ | | កុម្ភៈ ហ្វេវ្រីយេ | | មាឃ ផល្គុន | | មីនា ម៉ារ្ស | | ផល្គុន ចេត្រ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | សុ. | ៤ | ក. | ១ | ច. | ៦ | ក. | ១ | ពុ. | ៦ | ក. | ១ | ស. | ៨ | ក. | ១ | អ. | ៩ | ក. | ១ | អ. | ៨ | ក. |
| ២ | ស. | ៥ | | ២ | អ. | ៧ | | ២ | ព្រ. | ៧ | | ២ | អា. | ៩ | | ២ | ពុ. | ១០ | | ២ | ពុ. | ៩ | |
| ៣ | អា. | ៦ | | ៣ | ពុ. | ៨ | | ៣ | សុ. | ៨ | | ៣ | ច. | ១០ | | ៣ | ព្រ. | ១១ | | ៣ | ព្រ. | ១០ | |
| ៤ | ច. | ៧ | | ៤ | ព្រ. | ៩ | | ៤ | ស. | ៩ | | ៤ | អ. | ១១ | | ៤ | សុ. | ១២ | | ៤ | សុ. | ១១ | |
| ៥ | អ. | ៨ | | ៥ | សុ. | ១០ | | ៥ | អា. | ១០ | | ៥ | ពុ. | ១២ | | ៥ | ស. | ១៣ | | ៥ | ស. | ១២ | |
| ៦ | ពុ. | ៩ | | ៦ | ស. | ១១ | | ៦ | ច. | ១១ | | ៦ | ព្រ. | ១៣ | | ៦ | អា. | ១៤ | កោរ | ៦ | អា. | ១៣ | |
| ៧ | ព្រ. | ១០ | | ៧ | អា. | ១២ | | ៧ | អ. | ១២ | | ៧ | សុ. | ១៤ | កោរ | ៧ | ច. | ១៥ | បូណ៌ | ៧ | ច. | ១៤ | កោរ |
| ៨ | សុ. | ១១ | | ៨ | ច. | ១៣ | | ៨ | ពុ. | ១៣ | | ៨ | ស. | ១៥ | បូណ៌ | ៨ | អ. | ១ | រ. | ៨ | អ. | ១៥ | បូណ៌ |
| ៩ | ស. | ១២ | | ៩ | អ. | ១៤ | កោរ | ៩ | ព្រ. | ១៤ | កោរ | ៩ | អា. | ១ | រ. | ៩ | ពុ. | ២ | | ៩ | ពុ. | ១ | រ. |
| ១០ | អា. | ១៣ | | ១០ | ពុ. | ១៥ | បូណ៌ | ១០ | សុ. | ១៥ | បូណ៌ | ១០ | ច. | ២ | | ១០ | ព្រ. | ៣ | | ១០ | ព្រ. | ២ | |
| ១១ | ច. | ១៤ | កោរ | ១១ | ព្រ. | ១ | រ. | ១១ | ស. | ១ | រ. | ១១ | អ. | ៣ | | ១១ | សុ. | ៤ | | ១១ | សុ. | ៣ | |
| ១២ | អ. | ១៥ | បូណ៌ | ១២ | សុ. | ២ | | ១២ | អា. | ២ | | ១២ | ពុ. | ៤ | | ១២ | ស. | ៥ | | ១២ | ស. | ៤ | |
| ១៣ | ពុ. | ១ | រ. | ១៣ | ស. | ៣ | | ១៣ | ច. | ៣ | | ១៣ | ព្រ. | ៥ | | ១៣ | អា. | ៦ | | ១៣ | អា. | ៥ | |
| ១៤ | ព្រ. | ២ | | ១៤ | អា. | ៤ | | ១៤ | អ. | ៤ | | ១៤ | សុ. | ៦ | | ១៤ | ច. | ៧ | | ១៤ | ច. | ៦ | |
| ១៥ | សុ. | ៣ | | ១៥ | ច. | ៥ | | ១៥ | ពុ. | ៥ | | ១៥ | ស. | ៧ | | ១៥ | អ. | ៨ | | ១៥ | អ. | ៧ | |
| ១៦ | ស. | ៤ | | ១៦ | អ. | ៦ | | ១៦ | ព្រ. | ៦ | | ១៦ | អា. | ៨ | | ១៦ | ពុ. | ៩ | | ១៦ | ពុ. | ៨ | |
| ១៧ | អា. | ៥ | | ១៧ | ពុ. | ៧ | | ១៧ | សុ. | ៧ | | ១៧ | ច. | ៩ | | ១៧ | ព្រ. | ១០ | | ១៧ | ព្រ. | ៩ | |
| ១៨ | ច. | ៦ | | ១៨ | ព្រ. | ៨ | | ១៨ | ស. | ៨ | | ១៨ | អ. | ១០ | | ១៨ | សុ. | ១១ | | ១៨ | សុ. | ១០ | |
| ១៩ | អ. | ៧ | | ១៩ | សុ. | ៩ | | ១៩ | អា. | ៩ | | ១៩ | ពុ. | ១១ | | ១៩ | ស. | ១២ | | ១៩ | ស. | ១១ | |
| ២០ | ពុ. | ៨ | | ២០ | ស. | ១០ | | ២០ | ច. | ១០ | | ២០ | ព្រ. | ១២ | | ២០ | អា. | ១៣ | កោរ | ២០ | អា. | ១២ | |
| ២១ | ព្រ. | ៩ | | ២១ | អា. | ១១ | | ២១ | អ. | ១១ | | ២១ | សុ. | ១៣ | | ២១ | ច. | ១៤ | ១.ដ. | ២១ | ច. | ១៣ | |
| ២២ | សុ. | ១០ | | ២២ | ច. | ១២ | | ២២ | ពុ. | ១២ | | ២២ | ស. | ១៤ | កោរ | ២២ | អ. | ១ | ក. | ២២ | អ. | ១៤ | កោរ |
| ២៣ | ស. | ១១ | | ២៣ | អ. | ១៣ | | ២៣ | ព្រ. | ១៣ | កោរ | ២៣ | អា. | ១៥ | ១.ដ. | ២៣ | ពុ. | ២ | | ២៣ | ពុ. | ១៥ | ១.ដ. |
| ២៤ | អា. | ១២ | | ២៤ | ពុ. | ១៤ | កោរ | ២៤ | សុ. | ១៤ | ១.ដ. | ២៤ | ច. | ១ | ក. | ២៤ | ព្រ. | ៣ | | ២៤ | ព្រ. | ១ | ក. |
| ២៥ | ច. | ១៣ | កោរ | ២៥ | ព្រ. | ១៥ | ១.ដ. | ២៥ | ស. | ១ | ក. | ២៥ | អ. | ២ | | ២៥ | សុ. | ៤ | | ២៥ | សុ. | ២ | |
| ២៦ | អ. | ១៤ | ១.ដ. | ២៦ | សុ. | ១ | ក. | ២៦ | អា. | ២ | | ២៦ | ពុ. | ៣ | | ២៦ | ស. | ៥ | | ២៦ | ស. | ៣ | |
| ២៧ | ពុ. | ១ | ក. | ២៧ | ស. | ២ | | ២៧ | ច. | ៣ | | ២៧ | ព្រ. | ៤ | | ២៧ | អា. | ៦ | | ២៧ | អា. | ៤ | |
| ២៨ | ព្រ. | ២ | | ២៨ | អា. | ៣ | | ២៨ | អ. | ៤ | | ២៨ | សុ. | ៥ | | ២៨ | ច. | ៧ | | ២៨ | ច. | ៥ | |
| ២៩ | សុ. | ៣ | | ២៩ | ច. | ៤ | | ២៩ | ពុ. | ៥ | | ២៩ | ស. | ៦ | | | | | | ២៩ | អ. | ៦ | |
| ៣០ | ស. | ៤ | | ៣០ | អ. | ៥ | | ៣០ | ព្រ. | ៦ | | ៣០ | អា. | ៧ | | | | | | ៣០ | ពុ. | ៧ | |
| ៣១ | អា. | ៥ | | | | | | ៣១ | សុ. | ៧ | | ៣១ | ច. | ៨ | | | | | | ៣១ | ព្រ. | ៨ | |

តាមលំនាំប្រជាជនក្នុងរដ្ឋ គួរតែឋិតនៅក្នុងសភាពដ៏ស្ងប់ស្ងាត់ដោយប្រពៃ មិនគួរបើមានជនជាតិណាមួយមកបៀតបៀនសោះឡើយ; ខ្ញុំដូចជាកោតដែរអ្នកដែលបៀតបៀនគេ ដូចជាជ្រុលពេក គេមិនឈ្លោះនឹងខ្លួនៗ បែរមករករឿងគេ មនុស្សមិនដែលមានរឿងសោះចង់បង្កឲ្យមានរឿងបាន តាម-ព្រះពុទ្ធដីកាលោកសំដែងថា ( យើងមិនសម្លាប់គេ ៗ ក៏មិនសម្លាប់យើង យើងមិនរករឿងគេ ៗ ក៏មិនរករឿងយើង) ចុះចំណែកអ្នកកម្ពុជា មិនដែលមានសត្រូវនឹងជនណាមួយសោះ ម្ដេចក៏គេបែរតែមកបៀតបៀនឱ! គួរអាសូរអើម្ល៉េះទេកម្ពុជាអើយ! ។

នែមិត្តបរមិត្តកុំភ្លេច! ចំពោះករណីយ៍នេះឲ្យសោះព្រោះអ្នកគេចាត់ទុកជាអាជ្ញាកណ្ដាល បើអ្នកមិនមេត្តាដល់ជនអ្នកស្នេហាព្រះពុទ្ធសាសនាទេ អ្នកនឹងមានអយុត្តិធម៌នៅក្នុងខ្លួនហើយ ខ្ញុំហ៊ានធានាថារដ្ឋកម្ពុជៈ នឹងអ្នកកម្ពុជាពិតជាឋិតក្នុងសីលធម៌ដ៏សុខស្ងប់តាមវិន័យព្រះពុទ្ធសាសនាយ៉ាងពិតប្រាកដមែនអ្នកឮហើយ នេះជាបណ្ដាំក្រោយបំផុតរបស់ខ្ញុំ បានសេចក្ដីថា គួរអ្នកមើលសេចក្ដីសុខនឹងស្ងប់ដល់ជាតិនេះផងកុំភ្លេចឲ្យសោះ ។

សេះ ឱ! មិត្ត កាលបើខ្ញុំដឹងហេតុនេះហើយ នាំឲ្យខ្ញុំភ្លេចសេចក្ដីភិតភ័យទៅអនាគត កុំថាតែរូបអ្នកដែលនៅក្នុងរដ្ឋនេះអស់រយៈមួយឆ្នាំមកហើយ ត្រឹមតែខ្ញុំដែលមកដល់ភ្លាម ពុំទាន់យល់ទឹកចិត្តនៃអ្នកក្នុងរដ្ឋផងត្រាន់តែបានដំណឹងប៉ុណ្ណោះ ថ្លើម ប្រមាត់ បេះដូងខ្ញុំស្ទើររលួយព្រោះតែសេចក្ដីមេត្តា ។ ណ្ហើយមិត្តកុំព្រួយចំពោះរឿងនេះ ខ្ញុំធានាទុកលើខ្លួននឹងជួយបង្វែទឹកចិត្ត ប្រជាជាតិក្នុងលោកឲ្យស្របមតិគ្នាទៅតាមដំណើរសន្តិភាព ឲ្យឈប់ដណ្ដើមមុខមាត់គ្នាពីពេលនេះទៅ តែបើរឿងនេះខ្ញុំឃាត់មិនស្ដាប់ទេ ខ្ញុំនឹងបណ្ដោយទៅតាមចិត្តគេទៅវិញ បើខ្ញុំបណ្ដោយហើយ មិត្តឯងចាំមើលក្នុងមើលចុះ តូចនឹងអន្តរាយតាមតូច ធំនឹងអន្តរាយតាមធំ លោកទាំងមូលស្ទើររលាយព្រោះកម្លាំងអកុសលមូលទាំងបី ។

ពស់- ខ្ញុំដូចជាស្រៀវខ្លួនណាស់មិត្ត ចំពោះរឿងនេះ អាណិតមនុស្សលោកអស្ចារ្យហើយ ខ្ញុំលាហើយមិត្ត !

សេះ- សួស្ដីមិត្ត អញ្ជើញឲ្យសុខសប្បាយ !

ញូត-ហៀម

## អបាយមុខគឺអ្វី!

តពីលេខ ៣ មក

–

អបាយមុខទី ៣ – បានដល់ការដើរមើលល្បែងមហោស្រពផ្សេងៗ ។ បុរសក្ដី ស្ត្រីក្ដី កាលបើដឹងឮថា ល្បែងច្រៀងរាំក្ដីកំប្លែងមាននៅក្នុងទីណា ក៏ដើរចូលទៅកាន់ទីនោះ ហើយស្ដាប់ឬមើល

ល្បែងនោះៗ ដោយសេចក្ដីសប្បាយជាប់ចិត្តភ្លេចខ្លួនឥតនឹកនាប្រពន្ធកូន ឬប្ដីសីទ្រព្យសម្បត្តិដែលមាននៅក្នុងផ្ទះ, មិនតែប៉ុណ្ណោះ ខាតទាំងប្រាក់កាសដែលត្រូវចាយក្នុងល្បែងនោះៗផង, ខាតទាំងពេលដេកអត់ងងុយធង់, ខាតទាំងពេលដែលត្រូវប្រកបការងារកសិផង ។ ធម្មតាអ្នកមើលល្បែង មិនមែនធ្វើចិត្តឲ្យស្ងប់ស្ងាប់ទេ, បានឈ្មោះថាជាអ្នកពង្រីកបណ្ដែតបណ្ដោយចិត្តឲ្យរវើរវាយ វក់វៅក្នុងកាម-គុណកាន់តែខ្លាំងឡើងៗ ជួនកាលប្រុសលះលែងប្រពន្ធរបស់ខ្លួន រត់ទៅតាមស្រីអ្នកលេងល្បែងក៏មាន, ជួនកាលស្រីលះលែងប្ដីរបស់ខ្លួនរត់ទៅតាមប្រុសអ្នកលេងល្បែងក៏មាន, ចំណែកខាងប្រុសលបលាក់យកទ្រព្យរបស់ទៅឲ្យស្រី, ចំណែកស្រីលបលាក់យកទ្រព្យរបស់ទៅឲ្យប្រុស រឿងទាំងនេះ ក្នុងសម័យបច្ចុប្បន្នឥឡូវសឹងមានច្រើននៅស្រុកក្រៅនិងទីក្រុង, បើបុរសឬស្ត្រីដែលមានសភាពយ៉ាងនោះជាអ្នកមានអំណាច កាលបើប្រាក់កាសសំរាប់ចាយចាត់ចែងមិនគ្រប់គ្រាន់ទេ, ក៏តាំងប្រើឧបាយកលសង្កត់សង្កិនដោយផ្លូវអយុត្តិធម៌, ឥតនឹកអាណិតអាសូរដល់អ្នកផង, ដើម្បីយកទៅបង្គ្រប់បំប៉នកាមគុណទាំងនោះ ។ រឿងនេះ គួរឲ្យសង្វេគ គួរឲ្យនឹកស្ដាយពេកណាស់, បើប្រសិនជាយកចិត្តទុកដាក់ទំនុកបំរុងស្រុកទេស, ឲ្យបានប្រហែលគ្នានឹងយកចិត្តទុកដាក់ទំនុកបំរុងមាតុគ្រាម, ស្រុកទេសមុខតែនឹងមានសេចក្ដីចំរើនថ្កុំថ្កើងទាន់សម័យមិនខាន ។ សេចក្ដីដែលបានពណ៌នាមកនេះ ឈ្មោះថាជាប្រធាននៃសេចក្ដីវិនាស ។

អបាយមុខទី៤ – បានដល់ការលេងល្បែងភ្នាល់ស៊ីសង ។ ឯល្បែងភ្នាល់ស៊ីសងនេះ មានច្រើនយ៉ាង គឺបៀនិងធួជាដើម ។ បុរសស្ត្រីអ្នកចូលចិត្តប្រព្រឹត្តលេងល្បែងស៊ីសងណាមួយ, សុទ្ធតែមានបំណងចង់បានប្រយោជន៍ចំណេញមកឆាប់ៗ ប៉ុន្តែហេតុការណ៍ដែលពិតនោះ, មិនមែនត្រូវដូចគំនិតដែលប៉ងនោះទេ, បើទុកជាមានខ្លះ ក៏តិចណាស់ក្នុងលោកនេះ គួរអស់លោកអ្នកពិចារណាមើលដូច្នេះថា អ្នកមានភោគសម្បត្តិច្រើន រាប់ម៉ឺនរាប់-សែននៅជុំវិញខ្លួនយើងសព្វថ្ងៃនេះ, តើគេមានមកអំពីលេងល្បែង ឬគេមានមកអំពីប្រកបកសិកម្មនិងពាណិជ្ជកម្ម ? ប៉ុណ្ណេះក៏គង់អាចឃើញបាន ធម្មតាអ្នកប្រព្រឹត្តលេងល្បែងភ្នាល់, មិនដែលមានអ្នកណាមួយមានកំណើតទៅជាមនុស្សគ្រាន់បើទេ, ច្រើនតែទទួលរងគ្រោះថ្នាក់សេចក្ដីវិនាសច្រើនប្រការ គឺ: អ្នកប្រព្រឹត្តលេងល្បែង កាលបើខ្លួនឈ្នះ ក៏ប្រើអំណាចរំលោភអូសយកទ្រព្យសម្បត្តិអំពីអ្នកចាញ់ ៗ ក៏កើតសេចក្ដីក្ដៅក្រហាយ ចង់តៀរព្យាបាទគ្នាទៅវិញទៅមកក៏មាន, អ្នកចាញ់តែងដេកកើតទុក្ខថ្ងូរដក

ដង្ហើមធំ ស្ដាយទ្រព្យសម្បត្តិដែលវិនាសបាត់ទៅ រហូតដល់លែងចង់រស់នៅជាមនុស្ស ដោយប្រើវិធីចងកសំឡាប់ខ្លួនឯងជាដើមក៏មាន, អ្នកលេងល្បែងច្រើនមានឧបាយកុហកភូតភរបោកប្រាស់គេ ឲ្យតែបានដល់ដៃ ឬទោះបើទៅនិយាយពឹងពាក់ប្រស្រ័យកិច្ចការអ្វីៗ នឹងគេៗក៏មិនជឿ មិនយកជាប្រមាណ, ម្ល៉ោះហើយក៏ធ្លាក់ខ្លួនទៅជាមនុស្សថោក ឥតគេត្រូវការរាប់រក ។ ម្យ៉ាងទៀតល្បែងស៊ីសងអស់នេះ ច្រើនធ្វើទុក្ខដល់អ្នកនៅចំនេរ, ជួនកាលខ្វះប្ដីទៅធ្វើការបាត់, ឯប្រពន្ធនៅផ្ទះចាំនេរឥតការអ្វីធ្វើ ក៏តាំងវៃក្មួនតទល់នឹងប្រុសៗ ឬនឹងស្រីៗដូចគ្នា តាំងពីព្រលឹមទល់ថ្ងៃត្រង់ តាំងពីបែរពីថ្ងៃត្រង់ទល់ល្ងាច, ជួនកាលចំចាញ់អស់ ១រលីងពីខ្លួន ហើយក៏តាំងលក់បញ្ចាំគ្រឿងអលង្ការសំរាប់តាក់តែងរាងកាយ យកលេងទៀត, កាលណាបើប្ដីដឹង ក៏ទៅជាឈ្លោះទាស់ទែងលែងលះគ្នាក៏មាន, ទាំងនេះឯងជាប្រធាននៃសេចក្ដីវិនាសព្រោះល្បែងស៊ីសង ។

អបាយមុខទី៤– បានដល់ការសេពគប់នឹងបាបមិត្ត គឺមិត្តមានធម៌ដ៏លាមកអាក្រក់ថោក-ទាប ។ មនុស្សណា ដែលប្រព្រឹត្តធ្វើនូវអំពើអា-ក្រក់ជាហេតុនាំឲ្យកើតសេចក្ដីវិនាសដល់ខ្លួន ឬដល់អ្នកដទៃ មនុស្សនោះ ហៅថា បាបមិត្ត ។ បើអស់លោកអ្នកចង់ស្គាល់ថា មនុស្សបែបណាជាបាបមិត្តនោះ, តោងពិនិត្យសង្កេតដោយផ្លូវកាយវាចា នឹងចិត្តក៏អាចដឹងបាន ។ បណ្ដាមនុស្សក្នុងលោកអ្នកណាមួយទោះជាមនុស្សជាន់ខ្ពស់ក្ដី ជាន់កណ្ដាលក្ដី ជាន់ទាបក្ដី, សុទ្ធសឹងតែមានការងារត្រូវធ្វើជាប្រ-ក្រតី, បើមនុស្សសប្បុរសល្អ ការងារចេញមកតាមផ្លូវកាយក៏ល្អ, ចេញមកតាមផ្លូវវាចាក៏ល្អ, ចេញមកតាមផ្លូវចិត្តក៏ល្អ, មិនតែប៉ុណ្ណោះ ថែមទាំងជាអ្នកមានករុណាអាណិតអាសូរចំពោះអ្នកដទៃជានិច្ច, ធ្វើការអ្វីមិនអាងយសស័ក្តិមិនអាងអំណាច មិនប្រកបដោយអគតិលំអៀងព្រោះស្រឡាញ់ ព្រោះស្អប់ ព្រោះខ្លាចនោះទេ, មនុស្សបែបនេះ ហៅថា កល្យាណ-មិត្ត គួរសេពគប់រកយកជាមិត្តសំឡាញ់ ។ មនុស្សណាជាអ្នកប្រព្រឹត្តលេងល្បែងស៊ីសង, ជាអ្នកលេងស្រី, ជាអ្នកលេងផឹកសុរា, ជាអ្នកបញ្ឆោតបោកប្រាស់អ្នកដទៃដោយឧបាយកលណាមួយ, ជាអ្នកប្រើអំណាចរំលោភសង្កត់សង្កិនអ្នកដទៃ ដោយអាងយសស័ក្តិ ឬដោយអាងទ្រព្យសម្បត្តិ, មនុស្សបែបនេះ ហៅថា បាបមិត្ត, កុំចូលទៅសេពគប់រាប់រកយកជាមិត្តសំឡាញ់ឡើយ ។

អបាយមុខទី ៦– បានដល់ការប្រកបដោយសេចក្ដីខ្ជិលច្រអូស ។ សេចក្ដីខ្ជិលនេះ បើមានទៅលើរូបបុគ្គលណាហើយ, អាចនឹងពន្លិចឬបន្ទាបបុគ្គលនោះ ឲ្យធ្លាក់ទៅជាមនុស្សក្រីក្រល្ងង់ខ្លៅ មិនមាន

ណេះវិជ្ជានិងភោគសម្បត្តិ ។ ធម្មតាមនុស្សដែលលុះក្នុងអំណាចសេចក្ដីខ្ជិល បើនឹងធ្វើការអ្វី ឬរៀនចំណេះអ្វី, ច្រើនប្រើអាការទម្រន់ដោយយកអ្វីម្យ៉ាងៗមកធ្វើជាលេសគ្រឿងអាងរបស់ខ្លួន , ខ្លះអាងថាថ្ងៃនេះទៅព្រឹកណាស់, ល្ងាចណាស់, ត្រជាក់ណាស់, ក្ដៅណាស់, ឃ្លានណាស់, ស្រេកណាស់, ធ្វើការឬរៀនអ្វីពុំទាន់កើតទេ, ចាំសំរាកខ្លួនឬចាំបរិភោគអ្វីបន្តិចសិន សឹមធ្វើការឬសឹមរៀន; ការទម្រន់ខ្ជិលបែបនេះហើយដែលជាប្រធានធ្វើបុគ្គលនោះ ឲ្យដល់នូវភាពជាមនុស្សថោកទាបឥតគេត្រូវការរាប់រក ។

ម្យ៉ាងទៀត អស់លោក-អ្នកដែលធ្វើជាមេបាគេក្នុងក្រុមគ្រួសារនីមួយៗ ខ្លះមិនសូវប្រិតប្រៀនរំលឹកដាស់តឿនកូនឬក្មេង ដែលនៅក្នុងបន្ទុករបស់ខ្លួនឲ្យខំប្រឹងធ្វើការ ឬខំប្រឹងរៀនសូត្រតាមមុខការរបស់វាទេ, ច្រើនតែបណ្ដែតបណ្ដោយឲ្យក្មេងនៅទំនេរខ្ជិលដើរលេងតាមអំពើចិត្តលុះយូរទៅ ក៏ក្លាយទៅជាមនុស្សល្ងង់ខ្លៅ ខ្សត់ខ្សោយចំណេះវិជ្ជានិងភោគសម្បត្តិ មិនតែប៉ុណ្ណោះ មនុស្សល្ងង់ ឈ្មោះថាធ្វើជាតិត្រកូលនិងស្រុកទេសឲ្យថោកទាបថែមទៀត ។

សូមអស់លោក-អ្នកពិនិត្យសង្កេតមើលចុះ ទោសរបស់មនុស្សខ្ជិល, សព្វថ្ងៃនេះ នៅក្នុងក្រុងឃើញមានដេរដាស ទាំងស្រីទាំងប្រុស, ខ្លះដើរឈរអង្គុយដេករណែលក្រោមម្លប់ឈើ ឬតាមសំយាបផ្ទះក្បែរចិញ្ចឹមផ្ទល់, រកស៊ីគ្រាន់តែឲ្យរស់ត្រឹមមួយថ្ងៃៗប៉ុណ្ណោះ, បើនឹងធ្វើការ លុះណាតែមានគេក្រេន គេ-ជួល ទើបទៅធ្វើកើត, ឥតមានឧបាយគំនិតណាថាអញត្រូវធ្វើយ៉ាងនេះ យ៉ាងនោះសោះឡើយ, មនុស្សបែបនេះហើយ ដែលសំដែងអាការឲ្យឃើញថោកទាបដល់ជាតិនិងប្រទេស ។ មនុស្សខ្ជិលដូចបានពណ៌នាមកទាំងនេះ, ប្រសិនបើអស់លោក-អ្នកកាន់អំណាចបង្កើតរបរការអ្វីមួយ ដើម្បីត្រូវដល់មនុស្សទាំងនេះឲ្យមានការធ្វើឡើង, តទៅប្រហែលជានឹងមានសេចក្ដីចំរើនដល់ប្រទេសជាតិពុំខាន ។

ព្រះទេពសត្ថា គា. គួរ (ចន្ទមង្គលថេរ)

---

## ការប្រុងប្រយ័ត្ននៅវេលាមានផ្គររន្ទះ

រន្ទះធ្វើឲ្យបាត់បង់ជីវិតមនុស្សដូចគ្នានឹងទឹកជំនន់លង់លិច, ព្រោះធរណីរញ្ជួយនិងភ័យផ្សេងៗ ក្នុងលោកដែរ ។

ទីស្ដីការរដ្ឋមន្ត្រីក្រសួងអាកាសប្រទេសអង់គ្លេសប៉ាន់ថា បរិយាកាសដែលមាននៅលើផែនដីនេះជាទី-កើតនៃផ្គររន្ទះចំនួន ១៦ លានរាល់ឆ្នាំ គឺក្នុងមួយថ្ងៃមាន ៤៤០០០ ទ្វីបអាហ្វ្រិកភាគកណ្ដាល, ទីខាងត្បូងប្រទេសម៉ិចស៊ិក, ប្រទេសប៉ាណាមា , ភាគកណ្ដាលនៃប្រទេសប្រេស៊ីលនិងម៉ាដាគ័ស្ការ សុទ្ធតែជាទីដែលច្រើនតែមានផ្គររន្ទះក្នុងចំណោមទីកើតផ្គររន្ទះនេះមាន

តែកោះជ្វាមួយទៅដែលទទួលគ្រោះថ្នាក់ពីផ្គររន្ទះច្រើនជាងគេ ក្នុងមួយឆ្នាំមាន ២២៣ ថ្ងៃមានផ្គររន្ទះ ។

រន្ទះមានអាការបំផ្លែកគួរឲ្យចង់ដឹងណាស់ដូច-កាលពីក្នុងរដូវក្តៅមុននោះ នៅតាមឆ្នេរមហាសមុទ្រអាត្លង់ទិកខាងសហរដ្ឋអាមេរិក មានមនុស្សពីរនាក់ដែលកំពុងតែស្ទូចត្រីនៅលើទូកតូច ធ្វើដោយដែកថែបស្រាប់តែបានតិចមានផ្គររន្ទះភ្លៀង, កម្ររន្ទះមួយធ្លាក់ខ្ទាតមកលើដងសន្ទូចធ្វើដោយដែករបស់អ្នកស្ទូចត្រីម្នាក់ ហើយសសៀរចូលមកតាមខ្សែដែកតែកអាវ, ធ្វើឲ្យអ្នករងគ្រោះស្លាប់មួយរំពេច ឯម្នាក់ទៀតគ្រាន់តែរោលបន្តិចបន្តួច ។

នៅក្នុងរដ្ឋញូវយ៉កមានរន្ទះ មួយបាញ់ត្រូវតំនរដំឡូងបារាំងឆេះពាល់តែឆ្អិន ។

គេសង្កេតឃើញមានរន្ទះពីរយ៉ាងគឺរន្ទះទឹក និងរន្ទះភ្លើង រន្ទះទឹកបើបាញ់ម្តងៗ គ្រាន់តែធ្វើឲ្យធ្លាក់បែកធ្លុះធ្លាយទេ ឯរន្ទះភ្លើងតែបាញ់ចំហើយប្រទះលើអ្វីឆេះខ្ទេចខ្ទីអស់គ្មានសល់ ។ តាមដែលគេបានស្ទង់មើលរន្ទះភ្លើងមានកំដៅ ១៥០០០ អង្សា បានជាយើងឮសូរនៅពេលផ្គររន្ទះមកពីខ្យល់ក្តៅទឹងខ្យល់-ត្រជាក់ប៉ះទង្គិចគ្នារហ័សពេក

បើយើងឃើញថារន្ទះ បណ្តាលឲ្យមានគ្រោះកាចដូច្នេះហើយ តើមនុស្សត្រូវធ្វើដូចម្តេចដើម្បីប្រុងប្រយ័ត្នខ្លួន? លោកបណ្ឌិត ហាដ៍ បានរកឃើញវិធានដូចខាងក្រោម ។

១.- កាលណាជិតមានភ្លៀងផ្គរមកដល់បើអ្នកចង់ចេញទៅលេងកីឡាត្រូវបង្អង់ខានៈ, ទុកដាក់ទោចក្រយានរបស់ខ្លួននៅកន្លែងវិញ ។

២.- បើអ្នកចេញទៅក្រៅលំនៅហើយជួបប្រទះភ្លៀងផ្គរកុំឲ្យដើរ, ត្រូវរត់ម៉ូមាទៅរកកន្លែងជ្រកពួន បើរកបានគួរជ្រកនៅផ្ទះខ្ពស់ស្រឡះ បើមានផ្ទះបូត្រូវឲ្យទៅជ្រកនៅទីនេះ ព្រោះហេតុនឹងតែងមានឆ្អឹងដែកដែលអាចស្រូបទាញរន្ទះទំលាក់ទៅក្នុងដីបាន បើគ្មានផ្ទះនៅជិតទេ ត្រូវឲ្យក្រាបទៅលើដីឲ្យទាល់តែផុតភ្លៀងផ្គរ ។

៣.- ដើមឈើខ្ពស់ណានៅដាច់ពីគេក្តី, អាងទីខ្ពស់ក្តី, ចង្កេះក្អំទឹងដំបូកណាខ្ពស់ស្រឡះក្តីមិនត្រូវឲ្យជ្រកឡើយ (គេសង្កេតឃើញមានមនុស្សរងគ្រោះដោយរន្ទះ ដែលជ្រកក្រោមដើមឈើមួយក្នុងភាគបី បើជ្រកទីងព្រៃកំពោតល្អជាងជ្រកទីងគល់ឈើមួយដើម) ។

៤-. ជ្រកឲ្យឃ្លាតឆ្ងាយពីរបងដែកល្អស, បំពង់ដែកផ្សេងៗ ។

៥.- បើអ្នកកំពុងជិះទូកនៅកណ្តាលទន្លេត្រូវឲ្យបួលទៅចតនៅដីភ្លាម ។

៦.- បើនៅក្នុងផ្ទះរបស់អ្នកត្រូវថយឆ្ងាយពីបំ-ពង់ខ្យល់, បំពង់ភ្លើង, ទ្វារនឹងបង្អួច ហាមផ្តាច់មិន

ឲ្យស្ទូតទឹកនៅវេលាភ្លៀងផ្គរឡើយ ។

៧.- បើអ្នកធ្វើដំណើរដោយរថយន្តរថភ្លើង; ហើយមានភ្លៀងផ្គរ កុំឲ្យកម្រើកខ្លួនចុះឡើងឲ្យសោះ បើជានៅក្នុងយន្តហោះវិញ រឹតតែប្រសើរទៅទៀតព្រោះនៅក្នុងអាកាសយានគ្មានគ្រោះថ្នាក់ពីផ្គររន្ទះឡើយ ។

សម-ជាំង

# ដំណឹងព្រះពុទ្ធសាសនានៅសហរដ្ឋអាមេរិក

អំពី

**A Summanry of Buddhist Neree**

ប្រទេសសហរដ្ឋអាមេរិក

លោកស្រី សាន់ យ៉ាន់ ប្រ៉ត់ (**Mrs San yan Pratt**) ជាជនជាតិអង់គ្លេស អាយុ ៣៨ ឆ្នាំ មានបុត្រ ២ នាក់ បានបេ្តជ្ញាខ្លួនជាព្រហ្មចារិណី (សមាទានសីល ១០) ស្លៀកដណ្តប់សំពត់ពណ៌លឿងចាស់ នៅក្នុងខេត្ត ថាខូម៉ា (**Tacoma**) ក្នុងរដ្ឋវ៉ាស៊ីងតោន (**Washing Ton state**) សហរដ្ឋអាមេរិក នាងមានសេចក្តីជ្រះថ្លា និងមានសទ្ធា យ៉ាងមុតមាំក្នុងព្រះពុទ្ធសាសនា តាំងពីពុទ្ធសករាជ ២៤៦១ គ.ស. ១៩១៩ មកអំពីនាងធ្លាប់ស្រាវស្រះស្ទិទស្ទាលនឹងគិតក្នុងព្រះពុទ្ធសាសនាមួយរូប ។

ឯស្វាមីរបស់នាងនៅក្នុងប្រទេសអង់គ្លេសក៏បានសុំផែនខ្លួនជាពុទ្ធមាមកៈដូចនាងដែរ បតិបការបស ព្រហ្មចារិណី សាន់យ៉ាន់ប្រ៉ត់នេះគួរប្រៀបធៀបគ្នា បាននឹងពុទ្ធភាសិតថា "កាលបើបុប្ផូន កំពុងតែនឹងតជ្រប់នៅ ដូចជាគំនរនៃលំអងធូលី សាវ័ករបស់ព្រះតថាគតរមែងផុះផុះឡើង យ៉ាងល្អផង គន្ធល្អលើសលើពួកមនុស្សទាំងនោះបាន ដោយសេចក្តីចេះដឹងជុំវិញខ្លួន, ឬកាលបើមនុស្សប្រមាទ កំពុងដេកលក់នៅ, សាវ័កដែលមិនប្រមាទរមែងភ្ញាក់រឭកជានិច្ច កាលបើពួកជនត្រូវសេចក្តីងងឹតអន្ធការគឺទិដ្ឋិនានាកំពុងគ្របសង្កត់បិទបាំងនៅ, មានចំនួនតិចណាស់ ដែលអាចនឹងមានញាណចក្ខុ សំឡឹងមើលឃើញធម្មវិធីបាន ក្នុងនាមនៃពុទ្ធមាមកៈកម្ពុជា សូមអនុមោទនានឹងព្រហ្មចារិណី (**San yan Pratt**) សាន់ យ៉ាន់ប្រ៉ត់ ដែលមានសេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធ-សាសនារួមគ្នានឹងយើងផង ។

ប្រែពីសៀវភៅធម្មចក្កុ ភាគ ២២ ប្រចាំខែវិច្ឆិកា ២៤៧៩ ។

មហា មាស-ភោង

# អក្សរសាស្ត្រខ្មែរ ក្នុងបឋមយុគ

រាជសតាវត្សអក្សរសាស្ត្រ (ក. ស.) ទី៧

តាមប្រវត្តិសាស្ត្របានបញ្ជាក់ឲ្យយើងឃើញច្បាស់ថា ខ្មែរយើងក្នុងបឋមយុគ ជាជាតិ ១ ដែលមានអារ្យធម៌ខ្ពង់ខ្ពស់ នៅក្នុងដែនសុវណ្ណភូមិ ហើយអារ្យធម៌របស់យើងនោះផ្សាយចេញពីឥណ្ឌា,

អារ្យធម៌ឥណ្ឌាក្ដី អារ្យធម៌ខ្មែរក្ដី ក្នុងសម័យនោះ រុងរឿង-ថ្កុំថ្កើងយ៉ាងណា អ្នកប្រវត្តិសាស្ត្រអាចជ្រាបបាន ដោយមិនបាច់អធិប្បាយឲ្យពិស្ដារ ។

អក្សរសាស្ត្រខ្មែរក្នុងបឋមយុគ (សម័យនគរភ្នំ) នោះ ប្រហែលជាបានរុងរឿងតាមសភាពរបស់ជាតិមកហើយដែរ តែរលុបរលាយបាត់បង់ទៅជាច្រើន ឃើញនៅមានសេសសល់ខ្លះ នៅតាមសិលាចារឹក ។ សិលាចារឹកខ្មែរសម័យនគរភ្នំ និងសម័យនគរធំ មានជាភាសាសំស្ក្រឹត ជាភាសាខ្មែរ តែក្នុងសម័យនគរភ្នំមានចំនួនតិច សម័យនគរធំមានចំនួនច្រើនជាង, សិលាចារឹកជាភាសាខ្មែរសុទ្ធ តាមដែលគេបានស្រាវជ្រាវមកហើយ ឃើញមានពីត្រឹមសតវត្ស (គ.ស.) ទី ៧ ជាដើមមក គឺឃើញនៅប្រាសាទប្រាំល្វែង (យួនហៅថាប៉ម៉ូយ) ក្នុងតំបន់វាលភក់ ដែនកូសាំងស៊ីន ។ សិលាចារឹកនេះ ឥឡូវគេយកមកទុកនៅសារមន្ទីរអាល់ប៊ែរសារ៉ូ ក្នុងភ្នំពេញ លេខ D-,3 លោកសាស្ត្រាចារ្យ ហ្សក សឺដេស បានស្រង់យកទៅចុះក្នុងទស្សនាវដ្ដី សាលាបារាំងសែសនៅចុងបូព៌ាប្រទេស ត្រង់ភាគ ២ ទំព័រ ៧៩ ឆ្នាំ ១៩៤២ ។

ឥឡូវយើងចំឡងសេចក្ដីមួយអន្លើ មកចុះក្នុងទស្សនាវដ្ដីនេះជាគ្រាទី ២ តអំពីទស្សនាវដ្ដីបារាំងបានចំឡងផ្ដិតតាមច្បាប់ដើម តែប្រើអក្សរក្នុងបច្ចុប្បន្ន ដូចខាងក្រោមនេះ ៖

(១) កំព្រះ កម្រតាងអញស្រីអម្រាតកេស្វរ បុណ្យពោញកណ្ណទត្ត (២) ក អៃធចិត្ត ១ ក ក្ដុប ១ ក គ្រោក្វ ១ ក វ្ទិទត្ត ១ ក អទិត ១ ក មលេង ១ ក កា ១ ក ទេវបន្ទ្រ ១ (៣) ប តម្មង ១ ក ព្រ ១ ក សម្ទុះ ១ ក កន្សុម ១ ក ត្រមច ១ ក ស្តុយ ១ (៤) ក ត្វ ១ ក វុក ១ ក គូន ១ ក កន្តាង ១ ក អស្វិត ១ ក រម្យញ ១ ក គូនសិន ១ (៥) ក សំអុយ ១ ក សតក់រ ១ ក កន្ទេង ១ ក តាស្បុង ១ ក ចំដកព្រៈ ១ ក កន្ទក ១ ក ប៉ៃ ១ ក សំអុយសិន ១ ក អន្ទោក ១ ក សុហមូល ១ ក ព្រៅសិន ១ ក ម៌តគុក ១

កុ ព្រៅហូ ១ កុ អាស្ដ្រៈ ១ កុ អញ្ចាល្វ ស្រសាញ ១ ក មាន្ទអញ ១ កុ គូន ១ កុ សាម៉ន ១ កុ អលង ១ កុ អមោត្វង ១ កុ ប៉ោក ១ កុ ស្រី ១ កុ កន្ទិន ១ កុ បាដ្ហ ១ កុ ស្តេនរ ១ កុ កំព្រៈ ១ កុ ទុកព្រៈ ១ កុ សលក្វង បុងវៃ ១ កុ មេកម្ប្យារ ១ កុ អស្វរ ១ ។ ចប់ ។

អធិប្បាយថា ឈ្មោះ បុណ្យក្សូណ្ណទត្ត បានថ្វាយទាសកម្មករ ៣៦ នាក់ ទាសកម្មការិនី ១៧ នាក់ ទុកសម្រាប់បំរើព្រះស្រីអម្រាតកេស្វរ (< ឈ្មោះ ទេវតា ១ អង្គ) ។ ទាសកម្មករ គឺ អា អៃធចិត្ត, អា ក្ដុប, អា គ្រោក្វ (> គ្រោក្វ=ក្វា), អា វ្ទិទត្ត, អា អាទិត, អា មលេង, អាកា, ប តម្មង, អា ព្រ (> ព្រ), អា សម្ទុះ, អា កន្សុម, អា ត្រមច, អា ស្តុយ, អា ទេវបន្ទ្រ, អា ត្វ (> ទៅ,) អា វុក, អា គូន, អា កន្តាង, អា អស្វិត, អា រម្យញ, អា គូនសិន, អា សំអុយ, អា សតក់រ, អា កន្ទេង

អា តាស្បង៍, អា ចំដកវ្រះ(>ព្រះ), អា កន្ទេក, អា ថ្ងៃ(> ផ្ងៃ), អា សំអ៊ុយសិន, អា អេន្រ្ទាត, អា សុហាមូល, អា ព្រ៉ៅសិន(> ព្រៅសិន) អា មរិតតុក, ។

ពាសកម្មការិទី ១៧ គឺ មេ ព្រ៉ាញ > ព្រាព), មេ អាស្តរ្រះ(> ..ព្រះ),មេ អញ្ញា មេ្ល ស្រលាញ(> អញ្ញើផ្ទៃ...?), មេ មាន្រ្ទអញ, មេ កូន, មេ សាម៉ិនី; មេ អលង៍, មេ អមេត្យង៍,មេ កុបោត (>កុប៉ោ..), មេ ស្រី មេ កន្ទិន, មេ បាផ្កា (>ផ្កាឈើ), មេ ស៊ុរី មេ កំវ្រះ(ខំព្រះ) មេ ទុកវ្រះ>ទំទុកព្រះ) មេសល កូង បុងវៃវ(>...ប៉ុង...), មេ មេកម្សារ, មេ អសូរ ។

អធិប្បាយពាក្យថា វា ធឹង៍ គុា ក្នុងសិលាចារិកនេះ វា (វ៉ា ?) ជាពាក្យប្រាប់ភេទប្រុស, ជាពាក្យសាមញ្ញ សម្រាប់អ្នកធំហៅអ្នកតូច ធៀបប្រហែលនឹងពាក្យថា អា ក្នុងបច្ចុប្បន្ន ក្នុងទីនេះ ទើបប្រើថា អា ពាក្យថា កុ ជាពាក្យប្រាប់ភេទស្រី. ហើយជាពាក្យសាមញ្ញសម្រាប់អ្នកធំហៅស្រីអ្នកតូចជាន់ទាប ធៀបប្រហែលនឹងពាក្យថា មេ ក្នុងបច្ចុប្បន្ន តែធៀបនេះក៏មិនទាន់ត្រូវចំដែរ ព្រោះពាក្យថា កុ នៅប្រើដល់សព្វថ្ងៃនេះដែរ គ្រាន់តែប្រែក្លាយទៅជា ក ឬ កា និងក្លាយទៅជាសំឡេងផ្សេងដើងក៏មាន ។. ស្រីឈ្មោះគុន ហៅ កគុនឬកាគុន, ឈ្មោះអួច ហៅគួច ។ ក ឬ កា នេះគឺ ក្លាយមកពីពាក្យថាកុ នោះឯង ។

ប្រទេសចិនឡា (កម្ពុជា) ក្នុងសម័យនោះមានភាសាជាពិសេសមួយ ។ ពិតមែនតែសំឡេងប្រហែលគ្នានឹងភាសាខ្មែរបច្ចុប្បន្ន តែប្រជាជនខាងចម្ប៉ានឹងសៀមស្តាប់ភាសានេះមិនសូវយល់ ។ "មួយ ហៅ មិយ, ពីរ ហៅ ពីរ, បីហៅប៊ី, បួន ហៅ ប៉ាន់, ប្រាំ ហៅ ប៉ូកៀន ប្រាំមួយ ហៅប៉ូកៀនមិយ, ប្រាំពីរ ហៅ ប៉ូកៀនពិរ, ប្រាំបី, ហៅ ប៉ូកៀនប៊ី, ប្រាំបួន, ហៅ ប៉ូកៀនប៉ាន, ដប់ ហៅ តា ។

អាពុកថាប៉ាតូ, មាខាងអាពុកក៏ថាប៉ាតូ,ម៉ែថាមី, ម្ដាយមីងនឹងស្ដ្រីគួរជាទីគោរព ហៅថា មីដែរ,បងប្រុសច្បងថាប៉ាង់បងស្រីច្បងក៏ហៅប៉ាង់, ប្អូនប្រុសពៅ ហៅថាពៅវ៉ែន, មាខាងស្រី ចែឡាយ" (សេចក្ដីដកស្រង់ពីសារណា នៃប្រវៃតណីប្រទេសកម្ពុជារបស់លោកមេល្លឹយូត៍ បកប្រែអត្ថបទអ្នកដំណើរចិនជូតាគួន ។

ភាសានេះគ្រាន់តែឲ្យជនជាតិខ្មែរជ្រាបបន្តិចបន្តួចនូវឡាក់គោលមិនបានជាម៉ាំមួនទេ ។

នៅក្នុងយុគទី១នេះ, យើងមិនអាចស្រាវជ្រាវរកនាមនៃបណ្ឌិតពីសម័យនោះបាន, តែខ្ញុំសូមព្យាយាមតទៅទៀត បើបានឃើញនូវនាមបណ្ឌិតណាបានតែងសៀវភៅឈ្មោះអ្វីខ្ញុំនឹងចុះជូន តាមគួរការគទៅអនាគត ។

ចំណែកខាងលោកអ្នកដែលជាពហុស្សូត, សូមជួយស្រាវជ្រាវរឿងនេះ; បើឃើញមាននាមបណ្ឌិតណាឬរឿងរ៉ាវអ្វីជាគរ៉ី, ជាប្រណោមលោកជារឿងព្រេងសូមសរសេរ មកសមាគមមិត្តសាលាបាលីនឹង

ចាត់ឲ្យពិនិត្យ; ហើយលុះចាសួរចុះបាន, ទើបចុះដូនក្នុងសៀវភៅទស្សនាវដ្ដី "មិត្តសាលាបាលី" មិនបាន ទាន់ ។

# អ្វីជាកម្លាំងរបស់ជាតិ

តពីលេខ ៣ មក



ពាក្យដែលលោកប្រធានាធិបតីបានថ្លែងណែនាំនេះ បណ្ដាសមាគមនានាបាននាំយកទៅប្រតិបត្តិតាមគ្រប់ៗសមាគម ហើយបានពង្រីកផ្សាយទៅគ្រប់កន្លែង ។

កាលពុទ្ធសករាជ ២៤៦៦ រដ្ឋាភិបាលអាមេរិកាំងបានប្រមូលបញ្ជីចំនួនកុមារអនាថា ក្នុងប្រទេសមានចំនួនដល់ទៅ ៤០៤.៦៧៨ នាក់ ។ បណ្ដាកុមារទាំងនោះ កុមារដែលនៅក្នុងមន្ទីរអប់រំផ្សេងៗ ២០៤.៤៤១ នាក់ នៅតាមគ្រួសាររបស់ខ្លួន ១២១៤៤១ នាក់ នៅតាមកន្លែងសម្រាប់ចិញ្ចឹមដែលមិនបាច់បង់ថ្លៃ ៥១.១៦៤នាក់ នៅក្នុងកន្លែងដែលត្រូវបង់ថ្លៃ ២២.២៨១ នាក់, តាមស្ថិតិដែលប្រាកដថា កុមារដែលនៅក្នុងគ្រួសាររបស់អ្នកដទៃ ដែលគេកំពុងចិញ្ចឹមរក្សានោះ ការចំណាយតិចជាងទៅនៅក្នុងកន្លែងអប់រំដទៃៗ ជិតភាគ ១ ជាពីរ (គឺថាបើនៅក្នុងកន្លែងដែលមានគេកំពុងចិញ្ចឹមនោះ ការចាយវាយតិចជាងការដែលនៅក្នុងកន្លែងសម្រាប់អប់រំនោះ ១ ជា ២) ។

ក្នុងប្រទេសបារាំងសែស ការសង្គ្រោះកុមារអនាថា គួរកត់បានថាគេចាប់ផ្ដើមធ្វើតាំងពីសម័យព្រះចៅណាប៉ូឡេអុងមហារាជជាដើមមក, ក្នុងសម័យនោះ មានកន្លែងសម្រាប់ចិញ្ចឹមកុមារកំព្រា កុមារដែលរត់ចេញពីម្ដាយឪពុក (គឺមិននៅក្រោមឱវាទមាតាបិតា) និងកន្លែងសម្រាប់ចិញ្ចឹមកុមារវត្ត (ក្មេងវត្ត). ខាងរដ្ឋាភិបាលក៏បានជួយឧបត្ថម្ភដល់កុមារទាំងនោះ ដោយចំណាយប្រាក់ធ្វើជាទុនសម្រាប់ចាយវាយក្នុងការចិញ្ចឹមរក្សានោះ ទាំងក្នុងទីក្រុងនិងនៅខេត្តក្រៅ; នៅខេត្តក្រៅកន្លែងសង្គ្រោះកុមារអនាថា ត្រូវនៅក្រោមការត្រួតត្រារបស់ចៅហ្វាយខេត្ត ៗ ត្រូវធ្វើសេចក្ដីរាយការនោះឡើងផ្ទាល់ចំពោះរដ្ឋមន្ត្រីក្រសួងមហាផ្ទៃតែម្ដង នៅទីក្រុងក៏មានរបៀបដូចគ្នានឹងនៅខេត្តក្រៅដែរ ។ ចំណែកកុមារ

ដែលកំព្រាឪពុក (គឺឪពុកស្លាប់ក្នុងសង្គ្រាម) រដ្ឋាភិបាលបានជួយឧបត្ថម្ភ ដោយបញ្ជូនខ្លួនកុមារទាំងនោះឲ្យទៅនៅកន្លែងដូចបានពោលមកហើយ តែមានការសង្គ្រោះជាពិសេសផ្សេងដោយឡែកខ្លះ គឺឲ្យមានការបញ្ចឹមថែរក្សាដោយឲ្យនៅក្នុងកន្លែងពិសេសផ្សេងពីគេជាដើម ។

ក្នុងប្រទេសអាល្លឺម៉ង់ កាលពុទ្ធសករាជ២៤៦៥ រដ្ឋាភិបាលបានស្ថាបនាសភាការយុវជន ហៅថា (យូគេនដម្ត៍) សភានេះមានតាំងនៅគ្រប់ផ្នែករាជការមជ្ឈដ្ឋានតាំងនៅទីរួមខេត្ត នាទីមុខក្រសួងរបស់សភានេះ គឺជាអ្នកថែទាំបីបាច់រក្សាកុមារអនាថាគ្រប់រូបលក្ខន្តិកៈ កំណត់ឲ្យសភាការយុវជនមាននាទីជាអ្នកទាក់ទងសម្ពន្ធរវាងរដ្ឋនឹងកុមារ រវាងកុមារនឹងភ្នាក់ងារផ្សេងៗ ដែលមានសិទ្ធិត្រូវគ្រប់គ្រងកុមារទាំងនោះ គឺគេតាំងតុលាការសម្រាប់កុមារនឹងតុលាការសម្រាប់គ្រប់គ្រងជាដើម ។

នៅប្រទេសអាល្លឺម៉ង់ កាលពុទ្ធសករាជ២៤៧៨ មានស្រីមេម៉ាយហើយមានកូនផងនោះ ចំនួន៣៣០ ០០០នាក់ ដែលបានទទួលប្រាក់ជំនួយពីរាជការ ។

នៅប្រទេសទុរគី មានកន្លែងសម្រាប់សង្គ្រោះកុមារអនាថា ដែលគេបានស្ថាបនាឡើងនៅទីក្រុង "អិស្តាន់ប៊ុល" ជាច្រើនកន្លែង ក្រៅអំពីនោះ ក៏មានអង្គការសង្គ្រោះកុមារយ៉ាងសំខាន់មួយទៀត គឺអ្នកដែលមានសទ្ធាចិត្តជាកុសលទាំងឡាយ បានចាត់តាំងឡើង ហៅថា "សមាគមសង្គ្រោះកុមារនៃទុរគី" មានមន្ទីរចាត់ការនៅទីក្រុងអង្ការ៉ា ហើយមានសាលាបំបែកទៅតាមទីរួមខេត្ត និងរួមស្រុកផ្សេងៗទៀតជាច្រើនរយ សមាគមនេះ បានទទួលប្រាក់ជំនួយអំពីប្រជាជនជាចំនួនច្រើន ខាងរដ្ឋាភិបាលក៏បានជួយឧបត្ថម្ភខ្លះតាមសមគួរ, មុខក្រសួងរបស់សមាគម គឺត្រូវជួយថែទាំរក្សាកុមារ និងឧបត្ថម្ភឲ្យមានអង្គការសង្គ្រោះកុមារកាន់តែកើតមានឲ្យបានច្រើនឡើង ជាលំដាប់ហូរហែមក ។

ក្នុងប្រទេសអូស្ត្រាលី, ការសង្គ្រោះកុមារជាន់ដំបូង គេប្រើរបៀបរើសក្មេងយកមកចិញ្ចឹម ហើយចាត់ឲ្យមានក្រុមកុមារសង្គ្រោះសម្រាប់ថែទាំកុមារធំៗតែម្តង, ដំណាតមកក្នុងពេលថ្មីៗ នេះគេក៏បានផ្លាស់ប្តូររបៀបថ្មីវិញ គឺគេឲ្យក្មេងទៅនៅជាមួយនឹងមាតារបស់ខ្លួន ហើយឲ្យសោហ៊ុយជួយឧបត្ថម្ភស្រីមេម៉ាយដូចទំនងដែលប្រទេសអាល្លឺម៉ង់ បានធ្វើនោះឯង

កាលបើយើងពិចារណាមើលហេតុផលក្នុងការសង្គ្រោះក្មេងនាបុរាណសម័យនោះ ក៏នឹងឃើញជាក់ថា ទីវត្តអារាមខាងព្រះពុទ្ធសាសនានៅប្រទេសយើងជាកន្លែងសំខាន់ សម្រាប់សំណាក់អាស្រ័យរបស់កុមារទាំងឡាយ, ព្រះសង្ឃអាចគ្រប់គ្រងរក្សាក្មេងឲ្យបានសេចក្តីសុខ និងបង្ហាត់បង្រៀនចំពោះវិជ្ជាផ្លូវលោកនឹងផ្លូវធម៌ ប្រដៅទូន្មានក្មេងឲ្យមានសីលាចារិកវត្តដ៏ប្រពៃព្រមទាំងញ៉ាំងកុមារនោះៗ ឲ្យចេះស្រឡាញ់

ទំនៀមទំលាប់របស់ជាតិយើងមុតមាំផង, - ប៉ុណ្ណេក ប្រជាជន ក៏មានសទ្ធាជ្រះថ្លាពេញចិត្តជួយឧបត្ថម្ភ ដោយពេញទំហឹងក្នុងកិច្ចនេះ ។

វិធីសង្គ្រោះកុមារអនាថា ឲ្យបានសមល្មមនឹងការរស់នៅគ្រប់ៗរូបនោះ ក៏ដូចជាមិនទាន់មានវិធីណាមួយដែលអាចឲ្យសម្រេចផលបានដោយពេញលេញ នៅពេលថ្មីៗនេះអ្នកចិត្តវិទ្យានឹងអ្នកជំនាញការក្នុងរបៀបរក្សាទាំងឡាយ មានមតិស្របគ្នាថា ត្រូវទុកឲ្យក្មេងនៅក្នុងផ្ទះបានយូរៗព្រោះការរស់នៅក្នុងផ្ទះ ជាកិច្ចមួយ គួរបណ្ដុះបណ្ដាលឲ្យផ្ទុតផ្ជាបដល់ទឹកចិត្តរបស់ក្មេងតាំងពីនៅតូចៗ នៅឡើយ ៗ តាមមតិរបស់អ្នកសរសេរនេះយល់ឃើញថា ការដែលគួរចៀសវាងនោះគឺបើមាតាបិតាដែលល្ងង់មិនចេះថែរក្សាក្មេងឲ្យមានទិសដៅល្អ ដូចពាក្យបុរាណពោលទុកថា "ចិញ្ចឹមកូនឲ្យកើតពោរ" នោះក៏ត្រូវតែបំបែកកូនឲ្យទៅនៅផ្សេងពីមាតាបិតាបែបនោះ ការសំខាន់បំផុតក៏គឺការបដិបត្តិ ឬការថែរក្សា ព្រោះមាតាបិតាដែលបានសិក្សារៀនសូត្រក្នុងរបៀបថែរក្សាកូននោះ មានចំនួនស្តួចស្តើងណាស់, នៅអឺរ៉ុប មានប្រទេសខ្លះ មានធ្វើស្ថិតិកុមារអនាថា ដែលត្រូវគេបំបែកចេញអំពីមាតាបិតាឲ្យទៅនៅកន្លែងផ្សេង ហើយដែលមាតាបិតារក្សាមិនបានដិតដល់នោះ ឃើញថាមានចំនួនច្រើនជាងកុមារអនាថាដែលមាតាបិតាចិញ្ចឹមផ្ទាល់ខ្លួន មួយជាបី កុមារដែលត្រូវគេបំបែកចេញពីមាតាបិតាដូច្នេះ ត្រូវតែរកកន្លែងសម្រាប់ចិញ្ចឹមអប់រំឲ្យបានល្អជាងមាតាបិតាចិញ្ចឹមផ្ទាល់ខ្លួន ដូចយ៉ាងគេបញ្ជូនកុមារទៅផ្ទះដទៃជាដើម កុមារដែលគួរបញ្ជូនឲ្យទៅនៅក្នុងកន្លែងមានអាហារនឹងទីសំណាក់ស្រួលបួលនោះ គួរបានចំពោះក្មេងណាដែលមានជម្ងឺ កុមារដែលជាមនុស្សប្រៀប្រែកោមិនសមគួរនឹងបានកន្លែងមានឥស្សរភាពណាសំណាទេ, កុមារអនាថាខ្លះដែលមានគេទទួលយកទៅចិញ្ចឹមជាកូនធម៌ ទុកជាមានក័ព្ទកសនាជាងអ្នកដទៃ, តែក្មេងជំពូកនេះច្រើននាំឲ្យអ្នកទទួលចិញ្ចឹមរការចិត្តពល់គ្នា ព្រោះម្ដាយឪពុកបងប្អូនរបស់វា ចេះតែទៅរញ៉ាំរញ៉ៃវង្វេប នាយភាយ នាំឲ្យក្មេងនោះខូចចិត្តគំនិត, មានខ្លះពេលកុមារនោះធំធាត់ល្មមប្រើការបាន ក៏លបពន្យល់ណែនាំឲ្យរត់ត្រឡប់ទៅនៅផ្ទះដើមវិញ ។ រឿងដែលនាំឲ្យគេកើតសេចក្ដីរការចិត្តនេះ បុរាណបានចងជាគតិមួយបទថា "យកកូនគេមកចិញ្ចឹមទុក ដូចយកឈើពុកធ្វើជណ្ដើរ ពុំនោះដូចយកកូនក្រពើ ចិញ្ចឹមវាធ្វើកូនអាត្មា ពេលក្រោយគង់តែវាឲ្យគុណ ច្រើនបែបច្រើនពុនគ្រប់ប្រការ ធ្វើឲ្យអ្នកនោះក្ដៅទុក គ្រប់ពេលវេលាឥតស្រាកស្រាន្ត"។

នៅប្រទេសកម្ពុជាយើង, មានព្រះពុទ្ធសាសនាជាបង្គោល ដែលបុព្វបុរសរបស់យើងធ្លាប់គោរពបូជាអស់កាលជាអង្វែងឆ្នាំហើយនោះ, អនុជនខាងក្រោយតៗ មកជាលំដាប់ សុទ្ធតែដើរតាមលំអាននោះគ្រប់

គ្នា , ឯពាក្យប្រដៅក្នុងពុទ្ធសាសនាក៏មានខ្លឹមសារជាគោលសំខាន់ ៗ ច្រើនណាស់ មានពាក្យដំបូន្មានឲ្យមនុស្សមានមេត្តាចិត្តដល់មនុស្សជាតិទូទៅ ឲ្យប្រើមេត្តាកាយកម្ម មេត្តាវចីកម្ម មេត្តាមនោកម្ម ដល់គ្នានឹងគ្នា , កុំគប្បីបៀតបៀនគ្នាដោយការយកសក្តិទ្រព្យសម្បត្តិនិងបំណេះវិជ្ជាទៅសង្កត់ង្កិន ជិះជាន់គ្នាឡើយ ជាពាក្យសសេចក្តីឲ្យឃើញច្បាស់ថា ការសង្គ្រោះកុមារនៅប្រទេសយើង ជាកិច្ចមួយអាចកើតឡើងបានដោយងាយ ជាងប្រទេសឯទៀត ហើយអាចនឹងតាំងនៅបានយ៉ាងស្ថិតស្ថេរ ដោយសុវត្ថិភាពទៀតផង ។

យើងមានសេចក្តីសង្ឃឹមកក់ក្តៅយ៉ាងមាំ ថាអស់លោក-អ្នកដែលបានអានរឿងនេះហើយ គង់នឹងមានចិត្តប្រវត្តិនឹកឃើញថា នានាប្រទេស ទោះបីគេមានពលរដ្ឋច្រើនប៉ុណ្ណោះហើយ ក៏គង់គេមិនបោះបង់កុមារអនាថាចោលឡើយ , គេអាចរកមធ្យោបាយតាំងសមាគមសង្គ្រោះកុមារទាំងនោះបានជាដរាប ។

ឯប្រទេសកម្ពុជាយើងសម័យនេះ ទើបនឹងបង្កើតសមាគមកុមារសង្គ្រោះបាន ១ កន្លែងហើយ , គួណាស់តែអស់លោក - អ្នកជាគហបតីទាំងឡាយព្រមទាំងបណ្តាជនទូទៅ រួបរួមកំឡាំងគ្នាជួយឧបត្ថម្ភសមាគមកុមារសង្គ្រោះ ដែលទើបនឹងចាប់កំណើតថ្មីនេះតាមសមគួរដល់ធនធាន ឲ្យបានលូតលាស់ចំរុងចំរើនឡើងជាលំដាប់ ព្រោះប្រទេសយើងសព្វថ្ងៃកំពុងត្រូវការបង្កើតចំនួនពលរដ្ឋឲ្យច្រើន ដើម្បីជាកំឡាំងជួយកសាងប្រទេសជាតិឲ្យមានវឌ្ឍនភាពទាន់សម័យ ។

មហា - ឆាន់

---

## ទំនប់ ១០ ឆ្នាំ

តពីលេខ ៣ មក

លុះចូលបួលក្នុងព្រះជន្ម ១៩ ព្រះវស្សា , ព្រះ-រាជកុមារទន្ទឹងចាំឲ្យផុត ១ ឆ្នាំទៀត ដែលហាក់ដូច ១ សតវត្សរ៍ ។ ថ្ងៃមួយពួកមុខមន្ត្រីនិងព្រះរាជវង្សានុវង្សខ្លះខ្វាងរៀបចំពិធី ចំរើនព្រះជន្មវស្សាព្រះមហាក្សត្រមានការចាត់ចែងធ្វើបុណ្យជាឧឡារិកក្នុងព្រះ - រាជវាំង ពួកអាមាត្យនាំគ្នាក្អើតក្អើនសប្បាយអឺងកង ឯអ្នកដទៃទៀតក៏ខ្វក់ខ្វល់គ្រប់ ៗ គ្នា ។

ឃើញបានឱកាស ដែលទ្រង់បានរង់ចាំយូរឆ្នាំមកហើយដូច្នោះ ព្រះរាជកុមារលបបបព្រះអង្គចេញទៅក្រៅគេចចុះគេចឡើងពាល់តែផុតពីការគយឃ្លាំនៃពួកពល ដែលរវល់តែពិនិត្យការខុសត្រូវក្នុងពិធីបុណ្យឲ្យបានរៀបរយ ។ ព្រះរាជកុមារយាងទៅជិតស្ទឹងដោយត្រីត្រួចស្រាយទូក ដែលចតនៅទីនោះស្តេចចុះទៅគង់ក្នុងទូក បណ្តោយឲ្យអណ្តែតទៅតាមក្រសែទឹក ព្រោះទ្រង់ពុំចេះចែវ ។ កូនទូកក៏លយសន្សឹមៗ ទៅតាមដងស្ទឹងដេរដាសដោយផ្កា

គ្រប់ពណ៌ ក្រោមម្លប់ឈើទ្រឈឹងទ្រឈៃ ដែលមានបក្សតូចៗ ល្អ ចំណាប់ដៃគ្នា អែបយោលយំលើនល្ហើយ ៗ តែការបាត់ព្រះរាជកុមារពីព្រះរាជវាំងស្ងាត់មិនបានប៉ុន្មានទេ គេផ្អើលរកឈ្មួរមួយរំពេច , ពួកអាមាត្យរត់រកខ្វាត់ខ្វែងសព្វទីកន្លែង ពួកពលទ្វេទ្វាចុះឡើងប្រមូលគ្នា នឹកអែងខ្លាចក្រែងព្រះរាជកុមារស្តេចយាងចេញទៅលេងមាត់ស្ទឹង ទើបនាំគ្នាស្ទុះស្រទៅកាន់ទីគួរភ័យនោះ ៗ កូនទូកក៏បង្ហាញរាងឲ្យឃើញក្នុងរវាងដើមឈើពីរដើម នាំឲ្យអ្នកទាំងឡាយរីករាយសប្បាយចិត្ត ដោយនឹកស្មានថាអស់មានគ្រោះអ្វីហើយ ៗ ស្រាប់តែពីអ្នកតាស្ទឹងងើបផ្ងារឡើង នាំឲ្យពួកអាមាត្យនិងពួកពលភាន់ភាំងស្មារតីគ្រប់ៗគ្នា ខ្លះប្រឹងប្រែងស្រែកក្លាត់សំឡេង ខ្លះយកដុំថ្មគប់ ខ្លះវាយគោះឈើលាន់ទ្រហឹង ដើម្បីបន្លាចសត្វកំណាចឲ្យមុជទៅក្នុងទឹកវិញ តែការខះខំទាំងប៉ុន្មាននោះ ឥតបានផលសោះឡើយ ៗ

ក្រពើហែលលឿនស្ទើរជិតដល់ទៅរកទូក ទៅ-ដល់កាន់តែជិតណាស់ទៅហើយ ព្រះរាជកុមារក្លាហាន កន្ត្រាក់បានប្រាជាគ្រឿងអាវុធ រង់ចាំសត្រូវដោយឥតតក់ស្លុត ៗ មាត់ស្ទឹងទាំងសងខាងពាសពេញទៅដោយមនុស្សម្នាក្នាន់ក្នាប់ ដែលឈរមើលដោយស្ងៀមស្ងាត់ដោយភាន់តឹងចិត្ត ទំប្រឹងរែងខ្លួនអស់ ៗ ក្រពើចូលដល់ទូកព្រះរាជកុមារសំពងក្បាលឯប្រាក់អស់ទំហឹងដៃ សត្វចង្រៃឈឺខ្លាំងបំរះរមួលខ្លួនបែករលកខ្ទាល ដោយអំណាចសេចក្តីឃោរឃៅវាយកកន្ទុយបោកទូក ធ្លាក់ព្រះរាជកុមារក្នុងទឹកហើយវាហាមាត់ធំចង្រៀងត្របាក់ជាចំណី រួចក៏មុជក្នុងទឹកបាត់ទៅ ឯទូកក៏លិចក្នុងពេលនោះ គេឮសូរសព្ទយោបំសោកសៅតាមដងស្ទឹង ទ្រហឹងអឺងកងហាក់-កក្រើកប្រថពី ៗ ពួកពលពួកអាមាត្យ បណ្តារាស្ត្រកកកុញកៀបក្រានៅទីនោះ គ្មានឫទ្ធានុភាពនឹងជួយអនាគតមហារាជ ជាទីសង្ឃឹមមាំរបស់ខ្លួនឲ្យរួចព្រះជន្មបានឡើយ ប្រុសៗវាយគប់ក្បាល , ស្រីៗសំរក់ទឹកភ្នែកកន្ទក់កន្ទេញបំរះនទៀល ៗ

ដំណឹងទុក្ខព្រឺកដែលបុណ្យគគ្រឹកគគ្រេងដែលសេចក្តីរីករាយសប្បាយផ្សាយដល់ព្រះរាជវាំង យ៉ាងឆាប់រហ័ស ព្រះមហាក្សត្រនិងព្រះមហេសីស្ទុះទៅទីរង់គ្រោះទាំងព្រះភក្ត្រពេញយស បួងសួងបន់ស្រន់អស់ពួកទេពនិករអមរមេឃ ក្នុងចក្រវាឡ សូមឲ្យជួយស្រោចស្រង់ព្រះរាជឱរស ជាបណ្តូលបណ្តាច់ព្រះហឫទ័យ បើសម្រេចដូចសេចក្តីប្រាថ្នា ហើយនឹងរៀបពលីការបូជាជាឧឡារិកឲ្យសម្បើមអស្ចារ្យ ជាងដែលធ្លាប់បានធ្វើពីមុនៗមក , តែស្ងួនតូចនៅទ្រមឹងទ្រមើយធ្វើជាថ្លង់មិនឮពាក្យបួងបាច់អង្វរករសោះឡើយ ៗ ក្សត្រទាំងពីរព្រះអង្គផុតផ្សងសង្ឃឹម ទំនួនព្រះភរិយានឹងខ្លួនទាពេលដែលមានទុក្ខដ៏ធ្ងន់បែបនោះ ចប់ព្រះស្មារតីខ្ទប់ខ្លួនមិនបញ្ចេញអាការៈ រសាប់រសល់

កណ្តាលទីប្រជុំជន ស្តេចយាងស្ងប់ស្ងៀមត្រឡប់ទៅព្រះរាជនិវេសន៍វិញ ពួកពលទ័ពពួកអាមាត្យដើរទនមុខសញ្ជប់សញ្ជឹងហែហមព្រះអង្គទៅ ៗ បំណែកខាងប្រជារាស្ត្រមិនទៅណាទេ នៅកើតទុក្ខក្តុកក្តួលរំជួលចិត្តជាអនេក ៗ ការកំសាន្តទាំងឡាយឈប់ស្ងាត់ឈឹង តូរ្យតន្ត្រីបាត់លាន់ឮទៀត អាហារភោជនដ៏ប្រណីតថ្លៃថ្លា ត្រជាក់អស់នៅក្នុងភាជន៍មាសនិងប្រាក់ ព្រះរាជធានីទាំងមូលហាក់ដូចត្រូវសណ្តំស្ងៀមស្ងាត់មួយរំពេច ៗ យាងដល់ព្រះបរម-រាជវាំងកំបុំងពីក្នុកដៃទហើយមហាក្សត្រនិងព្រះអគ្គ-មហេសី ក៏បណ្តោយមោះមេញឲ្យធ្លាយចេញមកតាមបំណាំងហៀរហូរព្រះជលនេត្រ ស្រោចស្រប់ជោរជោតព្រះភក្ត្រាទ្រង់មិនអស់ព្រះទ័យ នឹងមិនបានរៀបចំសពព្រះរាជបុត្រឲ្យសមរម្យ តាមកិត្តិយសនោះ ទើបទ្រង់មានព្រះឱង្ការ ឲ្យនាំតំរួតបាតការបាចទឹកស្ទឹងយកសពព្រះរាជកុមារមកធ្វើបុណ្យតាមប្រវេណី ៗ លុះបានទទួលបង្គាប់ហើយ ពួកពលរាប់រយនាក់ព្រមទាំងបណ្តារាស្ត្ររាប់ពាន់នាក់នាំគ្នាចូលឆ្ងាយ លើកទំនប់កាត់ស្ទឹង, ដុំដីនឹងដុំឥដ្ឋនិងដុំថ្ម បាក់គរលើគ្នាទាំងបង្គីៗ កិច្ចការលឿនលឿនទៅមុខយ៉ាងរហ័ស ធ្វើតែមួយថ្ងៃក៏លើកទំនប់បានហើយស្រេច ទើបនាំគ្នាជុតបន្ទុះបាចទឹកឲ្យរីងទាំងយប់ ៗ ដល់ពេលអាធ្រាត្រទំនប់នោះធ្លាយទៅគេនាំគ្នាបាក់ដីបំពេញភ្លាម តែជាប់មិនបានយូរហើយទឹកត្រង់នោះហូរមិនជាខ្លាំងប៉ុន្មានទេ, សូម្បីប្រឹងប្រែងទប់យ៉ាងណាក៏ជាការឥតអំពើ ៗ

ភាល់តំនិត មេបាត់ការបានឲ្យខ្ទង់ស្គរប៉ាវគងគ្រប់ស្រុកគ្រប់ភូមិរកអ្នកចាំទំនប់ តែគ្មានអ្នកណាធ្វើយសោះ ពួកអ្នកប្រកាសដំណឹងប្រុងប្រៀបរៀបខ្លួននឹងវិលថ្កានកន្លែងវិញ ស្រាប់តែជួបប្រទះនឹងស្ត្រីមេម៉ាយក្មេងម្នាក់ មានផ្ទៃពោះចំនួន ៥ ខែ ៗ នាងក្រណាស់ទំដើរស្វែងសួររកការធ្វើ តាំងពីព្រលឹមម៉្លេះគ្រាន់បានអ្វីចិញ្ចឹមខ្លួននឹងម្តាយចាស់ជរា ដើរពីផ្ទះមួយទៅផ្ទះមួយ ឥតមានគេត្រូវការប្រើប្រាស់ឲ្យធ្វើអ្វីសោះ នាងចូលទៅជិតពួកអ្នករាយគង សាកសួរកិច្ចការគេ គេប្រាប់ថា:

"អ្នកអើយ! យើងត្រូវការជួលអ្នកចាំយាមទំនប់រហូតដល់បាចរីងស្ងួត ក្នុង ១ យប់យើងឲ្យ ១០ បាទ តើអ្នកព្រមទេ? ចាស បើ ១០ បាទខ្ញុំព្រមចាំ គេនាំទៅកាន់ទំនប់ ប្រាប់កន្លែងដែលនាងត្រូវចាំ ហើយគេប្រគល់ ១០ បាទឲ្យនាង នាងទទួលលុយដោយសេចក្តីត្រេកអរឥតឧបមា រៀបអាត្មាទៅផ្សារជិតនោះ ទិញម្ហូបអាហារយកទៅផ្ទះ តែនាងដើរមិនទាន់បានមួយជំហានផង ស្រាប់តែពេជ្ឈឃាតដែលនៅជិត យារដាវកាប់នាងដាច់ជាពីរកំណាត់រំពេច ហើយកប់នាងត្រង់នោះឯង រួចហើយគេសង់ខ្ទម ១ ឲ្យ គឺខ្ទមដែលយើងឈប់សំរាកជិតនោះឯង ដើម្បី

ឲ្យខ្មោចនាងចាំទិនប៉ាន ទើបគេហៅទិនប៉នោះថា ទិនប៉ ១០ ប៉ាទដកបមក ។ កិច្ចនេះជាទំនៀមពីបរមបុរាណ គេតែងសម្លាប់មនុស្សស្រីដើម្បីឲ្យរក្សាការកសាងធំៗ ។

តាំងពីនោះមក ទិនប៉លែងឆ្ងាយទៀត គេអាចបាចទឹកឲ្យរីងអស់ពីក្នុងស្ទឹង ចាប់ក្រពើសម្លាប់ វះពោះយកសពព្រះរាជកុមារ មកធ្វើបុណ្យជាទក្ខិណ តាមព្រះរាជប្រវេណី ។

អ្នករកជ័របានបញ្ចប់និទានរបស់គេដូច្នេះ ក្រោយដែលមហាក្សត្រទិវង្គតទៅ គេមិនដឹងជាព្រះរាជធានីដែលគ្មានក្សត្រគ្រប់គ្រងនោះ ទៅជាដូចម្តេចទេ នៅសល់តែស្នាមលំអានដែលគេអាចកត់សំគាល់តៗមក ដោយសារមានភស្តុតាងមិនសាប់ ពោលគឺបាតស្ទឹងរីងស្ងួត, ទិនប៉ ១០ ប៉ាទបាក់បែកទៅហើយ ក្នុងវេលានេះទីជ្រមដែលឃើញនូវមុខអ្នកនោះ ។ ពីអាធ្រាត្រដល់ភ្លឺ ឮសូរសំឡេងចំឡែក ចេញពីបាតស្ទឹងមក ចាស់ៗ និយាយថា នេះជាសំឡេងបិសាចនិយាយគ្នា ។ រឿងនេះមិនគួរឲ្យអ្នកជឿទេ, តែការណ៍នោះក៏ប្រាកដដល់អ្នកពីយប់មិញស្រាប់ហើយ ។

ហោង-យ៉ាង

## ដំណើរប្រក្រតីទិនសុរិយគតិ

តពីលេខ ៣ មក

លើចាក់មកក្រោមៗ ភាពនេះមានរូបទ្រង់ទ្រាយ បែបភាពជាក្អម ដោយហេតុអ្វី ខ្ញុំមិនអាចដឹងដល់ៗ គឺខែដែលគិតពី ថ្ងៃ ទី ១០ យ៉ាំងវីយេរទៅកាន់១៩ ហ្វេវ្រីយេរ ។ ភាពនេះមានហេតុ ទាក់ទងនឹងជោគវាសនាមនុស្សសត្វលោក, លោកធាតុ ចក្រវាឡ បុព្វហេតុ ដែលកើតភាពនេះ នោះស្រេចនឹងបណ្ឌិតខាងភាពសាស្ត្រហោរាសាស្ត្រឯនោះ ។

៣- មីនា: ឈ្មោះខែ ទី ១២ នៃសុរិយគតិតាមវចនានុក្រមខ្មែរភាគ ១, មាន ៣១, ថ្ងៃ ត្រូវគ្នានឹងខែម៉ាឃ (ខែទី ៣ បារាំងសែស) ។ មីនៈ ប្រែថាត្រី ។

តាមវចនានុក្រមបារាំង "ឡារុស្ស" មីនាត្រូវនឹងភាសា "**Les Poissons**" ប្រែថាត្រី គឺខែដែលគិតពីថ្ងៃទី១០ ហ្វេវ្រីយេរទៅដល់ថ្ងៃ ទី ២១ មារ្ស ។

៤- មេសា: តាមវចនានុក្រមខ្មែរ (ភាគ ១) មេសៈប្រែថា ពពែ ឬចៀម ឈ្មោះខែទី ១ នៃសុរិយគតិមាន ៣០ ថ្ងៃ ត្រូវគ្នានឹងខែ ទី ៤ បារាំងសែស

តាមវចនានុក្រមបារាំង "ឡារុស្ស" មេសាត្រូវនឹង ភាសា "**Bélier**" ប្រែថាចៀមឈ្មោល គឺខែនៃសុរិយគតិ គិត ពី ថ្ងៃ ទី ២១មារ្ស ទៅដល់ ២០ អាព្រីល ។

៥- ឧសភា : តាមវចនានុក្រមខ្មែរភាគ ១

ឧសភៈ ជាភាសាសំស្ក្រឹត ប្រែថា គោឈ្មោល គោទៀងក, គោបា ។ ឈ្មោះខែទី ២ នៃសុរិយគតិ ត្រូវគ្នានឹងខែម៉េ បារាំងសែស ។

តាមវចនានុក្រមបារាំង "ឡារុស្ស" ឧសភៈ

ត្រូវគ្នានឹង តារា "**Taureau**" ប្រែថា គោឈ្មោល ដូចគ្នា នឹងសត្វរាសី គិតពីថ្ងៃទី ២០អាព្រិលទៅដល់ថ្ងៃទី ២១មេ

៦ - មិថុនា: តាមវចនានុក្រមខ្មែរភាគ១ពាក្យ ថា មិថុន: ជាភាសាសំស្រ្កឹត ប្រែថា គូ, គូនៃបុរស នឹងស្រី; ឈ្មោះខែទី៣ នៃសុរិយគតិ មាន៣០ថ្ងៃត្រូវគ្នានឹង ខែយូ៉ាំង បារាំងសែស ។

តាមវចនានុក្រម បារាំង មិថុនា ត្រូវគ្នានឹងតារា "**Gémeaux**" ជាពាក្យមកពីភាសាឡាតាំង **Gemelli** ប្រែជាភាសាបារាំងថា **Jumeaux** , ភាសាខ្មែរ ថា "កូនភ្លោះ", មិនមែន គូនៃបុរសទេ ជាភាសាបារាំងថា "**Fiancé** " មិនមែន **Gémeaux** ទេ ខែនេះ គិតតាំងពីថ្ងៃទី ២១ មេ ទៅ ដល់ថ្ងៃទី ២២ យូ៉ាំង, គឺតារាពីរនៅជិតគ្នាមានរឿង តំណាលក្នុងគម្ពីរក្រេក ថាមាន បងប្អូនពីរនាក់ (កូនភ្លោះ) នាមកាស្ទ័រ នឹង ប៉ូលុក្ស ដល់ស្លាប់ទៅ ។ កើតជាតារាពីរ ហៅ ថា **Gémeaux** ។

៧ - កក្កដា : គឺកក្កដរាសី, ខែ ទី ៤ នៃសុរិយ-គតិ មាន៣១ថ្ងៃ ត្រូវ គ្នានឹងខែស៊ូយេត ។ កក្កដ:នេះ ជាភាសាបាលីប្រែថា "ក្តាម" ។

តាមវចនានុក្រមបារាំង កក្កដា ត្រូវគ្នានឹង **Signe de zodiaque** "**Cancer**" ជាភាសាក្រេក ប្រែថា ក្តាម ។ ដល់ព្រះអាទិត្យត្រាច់មកដល់ តារានេះគឺ ចូលទៅវង់មូលខាងជើង ដែលភាសាបារាំងហៅថា "**Tropique du Cancer**" ដែលស្ថិតនៅខាងជើងចក្រវាឡ (**Équateur**) ។

៨សីហា, គឺសត្វចតុប្បាទពួកមួយជាម្រឹគមាន អំណាចអង់អាច , ជាខែទី៥នៃសុរិយគតិមាន ៣១ ថ្ងៃត្រូវគ្នានឹងខែអ៊ូតបារាំង ។

តាមវចនានុក្រមបារាំង សីហាត្រូវគ្នានឹង តារា "**Lion**" ប្រែថាសិង្ហជារាសីដែលគិតតាំងពីថ្ងៃទី ២៣ ស៊ូយេតទៅដល់ថ្ងៃទី២៣ អ៊ូត ។

៩-កញ្ញា តាមវចនានុក្រមខ្មែរប្រែថា ស្រីក្រមុំ គួច, ស្រីជំទង់; កញ្ញារាសីឈ្មោះខែទី ៦នៃសុរិយគតិ មាន៣០ថ្ងៃត្រូវគ្នានឹងខែសេបតមប្រ៍បារាំង ។

តាមវចនានុក្រមបារាំងកញ្ញា ត្រូវគ្នានឹង **Signe de zodiaque** ថា "**La Vierge**" ប្រែថាស្រីក្រមុំ គឺរាសីដែលគិតពីថ្ងៃទី ២៤ អ៊ូតទៅដល់ថ្ងៃទី២១សេប-តមប្រ៍ ។

១០-តុលា : ប្រែថា ជញ្ជីង , ជាខែទី៧ នៃសុរិយគតិ, មាន ៣១ថ្ងៃ ,ត្រូវគ្នា នឹងខែអុកតូប្រ៍ បារាំង ។

តាមវចនានុក្រមបារាំង, តុលា ត្រូវគ្នានឹង **Signe de zodiaque** (ន័យតាមសុរិយគតិ) ថា: "**La Balance**" ប្រែថា ជញ្ជីង ព្រោះ ថាក្នុងពេលនោះ ថ្ងៃស្មើគ្នានឹងយប់គឺពីថ្ងៃ ទី ២៣ សេបតមប្រ៍ ទៅទល់នឹងថ្ងៃទី ២៤ អុកតូប្រ៍ ១៩៥៣

១១ វិច្ឆិកា ប្រែថា ខ្យាដំរី, ខ្ទួយ, ជាខែទី ៨នៃសុរិយគតិ មាន ៣០ ថ្ងៃ ត្រូវគ្នានឹងខែណោវែមប្រ៍ ។

វិច្ឆិកា, បើតាមវចនានុក្រមបារាំង ថា ជា ខែខាងសុរិយគតិ ថា **Scorpion** ប្រែថា ខ្យាដំរី ខ្ទួយ គិតតាំងពីថ្ងៃ ទី ២៤ ឧកតូប្រ៍ទៅដល់ថ្ងៃ ទី ២៣ វិច្ឆិកា ។

១២ - ធ្នូ ជាខែ ទី ៩ នៃសុរិយគតិ មាន ៣១ ថ្ងៃ, ត្រូវគ្នានឹងខែដេសមប្រ៍ ។

ធ្នូ, បើតាមវចនានុក្រមបារាំង, ថា **Sagihaire** ជាតារាមួយមានដូចជារូបសេះមួយកំណាត់ (ផងខ្លួនជើង,) មួយកំណាត់ទៀត មនុស្សប្រុស (ពីដើមទ្រូងឡើងលើ) មានដៃកាន់ធ្នូបាញ់, ជា ខែខាងសុរិយគតិ គិតតាំងពីថ្ងៃ ទី ២៣ វិច្ឆិកា ទៅដល់ថ្ងៃទី ២២ ធ្នូ ។

បើប្រៀបធៀបខែសុរិយគតិនៃខ្មែរបុរាណ (តារាសាស្ត្រ) នឹងតារាសាស្ត្រតាមគម្ពីរក្រិកឡាតាំង ឃើញថា ខុស គ្នាត្រង់ខែមករ នឹងពាក្យថាតារាពពែកុរន (**Capricorne**) ប៉ុណ្ណោះ ។

បើតាមប្រកតិទិនធំ ដែលគេបោះពុម្ពនៅទីក្រុងត្រយ្យ សតវត្ស ១៩, គេបានបញ្ជាក់អំពី តារា ទាំង ១២ នឹងការគមនាគមន៍ ចំពោះរូបមនុស្ស គឺ:

១ - មេសា ត្រូវត្រាក្បាល នឹងមុខ;

២ – ឧសភា ត្រូវត្រាលើ ក;

៣ - មិថុនា ត្រូវត្រា ស្មា,ដៃ;

៤ - កក្កដា ត្រូវត្រា ដើមទ្រូង;

៥ - សីហា ត្រូវត្រា ខ្នងនឹងឆ្អឹងជំនី

៦ - កញ្ញា ត្រូវត្រា ពោះ នឹងពោះវៀន

៧ - តុលា ត្រូវត្រាផ្ចិត, ចង្កេះនឹងខាងក្រោមពោះ

៨ - វិច្ឆិកា ត្រូវត្រាខាងភេទប្រុសស្ត្រី;

៩ - ធ្នូ ត្រូវត្រាខាងភ្លៅ;

១០ - មករ ត្រូវត្រា ក្បាលជង្គង់ទាំងពីរ;

១១ - កុម្ភៈ ត្រូវត្រាជើង;

១២ - មីនា ត្រូវត្រាម្រាមនឹងបាតខ្នងជើង ។

អ្នកណាកើតខែមេសា មានពលភាព, វិជ្ជានុភាព, ឋាមភាព, ជីវភាពមាំមួន តែត្រូវទទួលទុក្ខទោសច្រើនប្រការ ។

អ្នកណាកើតខែ ឧសភា សម្បូណ៌ដោយភោគ-ទ្រព្យ ខែមិថុនាមានចិត្តទន់ប៉ុនប្រសប់ តែឆាប់ប្រែ- ខែ កក្កដា មានចិត្តមិននឹងនួន ឆាប់នេះឆាប់នោះ មិនទោះត្រង់ណា, ខែ សីហា មានចិត្តសប្បុរស, ច្រើនទុកចិត្តគេ, តែឆាប់ខឹងឆាប់ជាដូចជាព្យុះសង្ឃរា. ខែ កញ្ញា មានភោគទ្រព្យច្រើន ខែ តុលា ចិត្តសុចរិតស្មោះត្រង់ ខែ វិច្ឆិកា មានចិត្តប្រាជ្ញាម៉ាំក្នុងកិច្ចការទាំងឡាយ បើត្រូវការប្រើមធ្យោបាយទុច្ចរិត ក៏ប្រើមិនខ្លាចបាបអកុសលអ្វីឡើយ ឲ្យតែការនោះសម្រេចទៅតាមបំណង ខែ ធ្នូ ចិត្តរហ័សចង់ធ្វើអ្វីធ្វើភ្លាម មិនគិតមុខក្រោយ, ខែមករគឺ សត្វពាក់កណ្ដាលពពែ

ញីពាក់កណ្ដាល ពាក់កណ្ដាលទៀតត្រីមករ, មានចិត្ត
ព្យាយាមទៅបន្តិចម្ដងៗ គិតសន្សឹមៗ ទាល់តែបាន
ការទើបសម្រេច, ខែ កុម្ភៈ, ចិត្តចេះប្រែមធ្យោបាយ
ទៅតាមកាលៈទេសៈ, បើមិនទើតផ្លាស់ក្លាយចិត្តមិនរឹង
រូស, ខែ មីនា, មានចិត្តប្រាថ្នាហួសហេតុ, ច្រើនកើត
ទុក្ខលំបាក,មិនសូវបានសេចក្ដីសុខ ។

* *
*

## បកិណ្ណកកថា

នៅពិភពលោកមានភាសាផ្សេងៗគ្នា ចំនួន ២៧៩៦ភាសា ។ ជនជាតិដែលពោលភាសាអង់គ្លេសមាន២៧០លាននាក់ ។

ក្នុងមនុស្ស២៧០លាននេះមានជនជាតិ អាមេរិកាំង ជាងពាក់កណ្ដាល ពោលភាសាអង់គ្លេស ។

ព្រះធរណី ទម្ងន់ទាំងអស់, ៥.៨៧៥. ២០០.០០០.០០០.០០០.០០០តោន, មាឌ, ១.០៨០លានគីឡូម៉ែត្រត្រីគុណ ១.០៨០.០០០.០០០ ។

ព្រះអាទិត្យ ទម្ងន់៥.៨៧៥.២០០.០០០.០០០ ០០០.០០០×៣៥៤.៩៣៦=២០៨៥៣.១៩៩.៨៧ ២០០.០០០.០០០.០០០.០០០ តោន រុក្ខជាតិគឺបៅបាប់ដែលដុះនៅប្រទេសសេណេគ័លមានអាយុ៦០០០ឆ្នាំ, រុក្ខជាតិ "ស៊ីប្រែនៅប្រទេសរ៉ាគ្រុយ អាយុ៥.០០០ ឆ្នាំរង្វង់ដើម ១៦ម ។ ចំនួនវត្តកម្ពុជា ១៩៥៤:២៧៦៤វត្ត , វត្តមហានិកាយ, ២.៦៦៣, វត្តធម្មយុត្ត , ១០១ ។ ចំនួនពុទ្ធសាសនិកជនក្នុងពិភពលោក, ៥៥០.០០០.០០០។ព្រះនាមព្រះ សិរីទេពកុញ្ញារ , ព្រះទំនាំងកុញ្ញាសា ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង គឺ: "ព្រះសិរីទេពកុញ្ញារបវរ សេតវង្សបមពង្សឯករតនៈវិឌ្ឍមង្គលភក្ត្រាគតល វិមលគតេជ្ជន នរេន្ទ្របាទៈ វរកម្ពុជរដ្ឋ តិរេកឯកហត្ថ រាជធានី បុរីរម្យឧត្តមសួស្ដី" កាលពីថ្ងៃ ទី ២៥មេសា១៩៤១, ថ្ងៃដែលព្រះបាទសម្ដេចព្រះនរោត្តមសីហនុវរ្ម័ន ព្រះមហាក្សត្រិយប្រទេសកម្ពុជា ទ្រង់ឡើងសោយរាជសម្បត្តិ វេលាថ្ងៃរសៀលទៀបអស់ពន្លឺព្រះអាទិត្យ,ក៏កើតអស្ចារ្យដោយមហាមេឃបណ្ដាលឲ្យឃើញពន្លឺរស្មី ជាពណ៌ផ្កាយចូល របូត ដល់ក្នុងផ្ទះ ហើយមានខ្យល់បក់បោកយ៉ាងខ្លាំងហាក់ដូចជាទីងកៀន ។

រ៉ាយ-ប៊ុត

---

## ប៉ៅស្ដែងទន្សាយធ្វើដំណើរ

តពីលេខ៣មក

ដល់មក គ.ស. ១៧៦៨, ពួកមហាម៉តបានចូលទៅលុកលុយប្រទេសឥណ្ឌា ដេញពួកគូរកាស (**GourKas**) ខ្ចាត់ខ្ចាយសាយភាយចូលមកដល់ប្រទេសនេប៉ាល់ ។ គ.ស.១៧៩០, ពួកនេះមានបំណងចង់ចូលទៅភូមិភាគទីបេត៍, តែទទួលពួកចិននាំគង់ទ័ព



មកទប់ទល់បាន, ពួកនេះទៅជាពួកគណសម្ពន្ធ(១) បាន នាំសួយសារអាករឲ្យប្រទេសចិនរហូតមកដល់ គ.ស. ១៩១១ ។

គ.ស. ១៧៩១, ប្រទេសនេប៉ាល់បានចុះសន្ធិសញ្ញាខាងពាណិជ្ជកម្មជាមួយនឹងប្រទេសអង់គ្លី-តែរ ។ តែពួកជនជាតិនេប៉ាល់មិនបានប្រតិបត្តិតាមកិច្ចនៃសន្ធិសញ្ញានោះ ពួកអង់គ្លេសបានប្រកាសសង្គ្រាមនឹងពួកនេប៉ាល់, ដល់មក គ.ស. ១៨១៦ រដ្ឋាភិបាលអង់គ្លេស បានឲ្យរដ្ឋាភិបាលនេប៉ាល់ទទួលចាត់តាំងរេស៊ីដង់អង់គ្លេសមួយនៅទីក្រុងកាតម៉ង់ឌូ ។ តមកមានសម័យមួយកើតចលាចលក្នុងស្រុក, ដល់ ១៨៤៥ បុគ្គលម្នាក់នាមស៊ុកបាហាឌុរ ( Joug Bahadour ) បានឡើងជាក្សត្រសោយរាជ្យនៃប្រទេសនេប៉ាល់ ។

នៅក្នុងរជ្ជកាលស្ដេចនេះ ច្បាប់គ្រប់គ្រងប្រទេសមានកែប្រែម្រឹងថ្មីជាច្រើន ដល់ គ.ស. ១៨៥៧, មានកើតបដិវត្តន៍នៅប្រទេសឥណ្ឌា, ប្រទេសនេប៉ាល់ ក៏នាំគ្នាទ័ពទៅជួយប្រទេសអង់គ្លីតែរ ជាជំនួយក្នុងការជួយបង្ក្រាបពួកឧទ្ទាម(១) ។ ដល់មកគ.ស. ១៨៧៧, ព្រះបាទស៊ុកបាហាឌុរទទួលទិវង្គតមានកើតចលាចលនៅក្នុងប្រទេសរហូតមកដល់ គ.ស. ១៨៨៥, ទើបមានព្រះរាជាមួយអង្គព្រះនាមព្រះបាទចន្ទ្រចំចិន ( Chandra Cham chén ) ជាចៅព្រះបាទស៊ុកបាហាឌុរ ទ្រង់ឡើងសោយរាជ្យសម្បត្តិតសន្តតិវង្សមក ។ ស្ដេចនេះទ្រង់បានជួយប្រទេសអង់គ្លីតែរក្នុងពេលដែលធ្វើសង្គ្រាមនឹងប្រទេសទីបេត៍ (គ.ស.១៩០៤,) ព្រមទាំងមហាសង្គ្រាមសាកលលោកទីមួយ, ១៩១៤-១៩១៨ ហើយដល់មក គ.ស.១៩១៩ បានទៅជួយសង្គ្រាមប្រទេសអង់គ្លីតែរ ដែលជាគូសត្រូវនៃប្រទេសអាហ្គានិស្ថាន ។ ព្រះមហាក្សត្រនេះទ្រង់បានបំបាត់ខ្ញុំទាសភាព មិនឲ្យមាននៅក្នុងប្រទេស ។ ប្រទេសនេះ, ពិតមែនតែនៅក្រោមបង្គាប់បញ្ជានៃនាយទាហាន ដែលដណ្ដើមរាជសម្បត្តិបានដោយការប្រើអាវុធ, មិនមែន

(១) ពួកគ្រួសារច្រើនក្រុមលះទៅនៅក្នុងបង្គាប់បញ្ជានៃមនុស្សម្នាក់ ដែលគេទុកជាមេ, ជានាយក ឬ ជាស្ដេច ។

(១) ពួកបះបោរ

ដោយប្រជាមតិនោះកំពិត ចំពោះការរៀបរយក្នុងប្រទេសក៏បានសន្តិភាពដោយប្រពៃ មិនបាច់ទទួលបង្គាប់ពីប្រទេសសេរីណាឡើយ មានតែអ្នកប្រតិភូព្រឹទ្ធិកនឹងមន្ត្រីនៃប្រតិភូនេះទេ ដែលមានសិទ្ធិនៅក្នុងប្រទេសនេះបាន" នេះជាប្រវត្តិសាស្ត្រណេប៉ាល់ដោយសង្ខេប ។

នៅ "ស្ថានទន្សាយ" បានថ្លែងសេចក្តីអំណរជាអនេកប្បការ ចំពោះលោកគាព្រិទ្ធបាលតទៅទៀតថាៈ លោកគាបានជ្រាបព្រឹត្តិការណ៍ ដែលកើតក្នុងប្រទេសនេះពីថ្ងៃទី៧–៨វិច្ឆិកា ១៩៥០ ឬ?

លោកគាព្រិទ្ធបាល– នៅឯងចាំប្រវត្តិសាស្ត្រប្រទេសណេប៉ាល់ជាងគាទៅទៀត ។ ក្នុងពេលនោះមានពួកក្រុមយទិស្តចិន បានចូលទៅលុកលុយភូមិភាគទីបេត៍ ចំពោះព្រះមហាក្សត្រដែលសោយរាជសម្បត្តិនៅប្រទេសណេប៉ាល់ ទ្រង់មានព្រះរាជបំណងចង់ទៅរក្សាព្រះអង្គឯមន្ទីរព្យាបាលព្រះរោគ នាញូវដេលី ប្រទេសឥណ្ឌាដោយមានរោគាពាធ ។ ព្រះមហាក្សត្រដែលទ្រង់អាពាធនោះ ព្រះនាមមហារាជវិភុពនៈត្រិភុននៈ (Maharadja vi bhubana Trèbhunana) គាប៊ីណេត៍នៃព្រះបរមរាជវាំង មិនចង់ឲ្យព្រះមហាក្សត្ររបស់ខ្លួន យាងចេញពីព្រះរាជអាណាចក្រឡើយដោយក្នុងពេលនេះ កំពុងមានព្រឹត្តិការណ៍នៅប្រទេសទីបេត៍ ដែលមានព្រំដែន ១ជាប់នឹងប្រទេសណេប៉ាល់ ។

បើតាមដំណឹងពីស្ថានទូត នៃប្រទេសណេប៉ាល់ប្រចាំទីក្រុងញូវដេលី ជាព្រះមហាក្សត្រទ្រង់យាងចេញព្រះបរមរាជវាំងកាត់មង់ឌូ ហើយទ្រង់យាងទៅសុំពឹងព្រះអង្គនៅស្ថានទូតឥណ្ឌា ប្រចាំទីក្រុងកាត់មង់ឌូ តែព្រះអង្គទ្រង់ពុំបានប្រឹក្សាការនោះនឹងរដ្ឋាភិបាលរបស់ព្រះអង្គសោះឡើយ ។ ព្រះមហាក្សត្រទ្រង់យាងចេញមួយអន្លើ នឹងព្រះរាជតាយាយ ទាំងព្រះរាជបុត្របង្អួនផង ។ លោកនាយករដ្ឋមន្ត្រីបានចាត់រដ្ឋមន្ត្រីជាច្រើន ឲ្យចូលទៅក្រាបបង្គំគាល់ព្រះមហាក្សត្រសួរហេតុ ដែលព្រះអង្គទ្រង់មានព្រះរាជបំណងយាងចោលព្រះបរមរាជវាំង យាងទៅកាន់ប្រទេសឥណ្ឌា តែព្រះមហាក្សត្រទ្រង់មិនព្រមទទួល; ដល់លើកទីពីរព្រះរាជានៅតែពុំព្រមព្រះរាជានុញ្ញាតទៀត លោកនាយករដ្ឋមន្ត្រីយល់ថា ព្រះរាជចរិយាព្រះមហាក្សត្រ ដែលទ្រង់បានធ្វើបែបនេះជាទំនាស់នឹងច្បាប់រដ្ឋធម្មនុញ្ញ ហើយមិនសមហេតុផលផង ។ រដ្ឋសភាណេប៉ាល់បានបើកសម័យប្រជុំជំនាន់ពិសេស ហើយបានប្រកាសជាឯកច្ឆន្ទថា ព្រះរាជវង្សានុវង្ស ដែលយាងចេញពីព្រះបរមរាជវាំងទុកជាផុតសិទ្ធិ ក្នុងការតមតារយករាជសម្បត្តិតទៅអនាគត ។ រដ្ឋសភាក៏បានចេញប្រកាសលើកព្រះរាជនត្តានៃព្រះមហាក្សត្រមុន ដែលមានព្រះជន្មាយុ ៣ ឆ្នាំ ជាព្រះរាជបុត្រទីពីរ នៃព្រះរាជតាយាយ ឲ្យឡើងជាក្សត្រគ្រងរាជ្យប្រទេសណេប៉ាល់ ។

បើតាមដំណឹងពីស្ថានទូតដដែលនេះថាៈ “ប្រហែលជាប្រាំមួយសប្តាហៈមក មានក្រុមបះបោរមួយក្នុង មានបំណងនឹងធ្វើពឃាដចំពោះព្រះមហាក្សត្រអង្គថ្មី និងឃាដកម្មចំពោះរដ្ឋមន្ត្រីធំៗ តែគេបានអង្កេតរកហេតុភេទនោះឃើញជាមុននៅទីក្រុងកាតមង់ឌូ” ។

ក្នុងពេលវិបត្តិនៃប្រទេសណេប៉ាល់យ៉ាងនេះ មានវិទ្យុឥណ្ឌៀបញ្ជាក់ថា រដ្ឋាភិបាលណេប៉ាល់ព្រមទទួលព្រះមហាក្សត្រ ដែលទ្រង់ចាកចេញពីរាជសម្បត្តិ យាងទៅគង់នៅប្រទេសឥណ្ឌៀនោះ ឲ្យគង់ក្នុងរាជ-សម្បត្តិវិញដោយការស្នើពីរដ្ឋាភិបាលឥណ្ឌៀមក ។ មានអាកាសយានពីរ បានចេញពីប្រទេសឥណ្ឌៀនៅថ្ងៃ១០វិច្ឆិកា មកទទួលព្រះមហាក្សត្រ ណេប៉ាល់ ឯស្ថានទូតឥណ្ឌៀទៅកាតមង់ឌូ ។ ក្នុងពេលក្រោយ, ពួកក្រុមខាងព្រះមហាក្សត្រណេប៉ាល់ ដែលមកពីប្រទេសឥណ្ឌៀ បាននាំគ្នាឆ្លងកាត់ព្រំដែនប្រទេសណេប៉ាល់ ប្រាំបួនកន្លែងចូលទៅកាន់ទីក្រុងកាតមង់ឌូ ។ ពួកទាហាននេះហៅថាកងទ័ព“សមា-ជៈណេប៉ាល់” បានចូលទៅដល់ភូមិក្រៅនៃទីក្រុងកាតមង់ឌូ ហើយបានទៅជួបប្រទះគ្នានឹងកងទ័ពរដ្ឋាភិបាលណេប៉ាល់ៗ ពួកកងទ័ពសមាជៈណេប៉ាល់មានបំណងតស៊ូដើម្បីនឹង ដកប្រជារាស្ត្រនឹងព្រះមហាក្សត្រណេប៉ាល់ចាកចេញពីវង្សត្រកូលរាណៈ ។ ពេលនោះទ័ពខាងសមាជៈកបដោយជោគជ័យ ។ នៅទីក្រុងបិរគញ្ជ( Birganj ) នាប្រទេសណេប៉ាល់ដែលកងទ័ពខាងសមាជៈវាយយកបាន តាមដំណឹងនៃទីភ្នាក់ងារ “United presse of India” មានពួកប្រជារាស្ត្រជាងប្រាំពាន់នាក់មកស្រែកថ្វាយពរជ័យព្រះមហាក្សត្រ ។ កងទ័ពសមាជៈ ចាត់ការចាប់បានឈ្លើយប្រហែល ១.២០០នាក់ ។

ស្ថានទូតប្រទេសណេប៉ាល់ ប្រចាំទីក្រុងដេលហ៊ីបានផ្សាយថា រដ្ឋាភិបាលណេប៉ាល់បានធ្វើសាសន៍ទំនាស់ចំពោះប្រទេសឥណ្ឌៀថាប្រទេសនេះ ជាមូលដ្ឋាននៃកិច្ចប្រតិបត្តិការខាងទាហាន ទៅកាន់រដ្ឋាភិបាលកាតមង់ឌូ; សាសន៍នោះបញ្ជាក់ថានឹងមានសន្និសីទ ដែលមានសមាជិករដ្ឋាភិបាលទាំងពីរទៅប្រជុំ ដើម្បីនឹងសម្រេចអំពីរឿងនេះ ។

តាមដំណឹងពីញូវដេលហ៊ីក្នុងថ្ងៃទី ១៨ វិច្ឆិកា, ពួកកងទ័ពខាងព្រះមហាក្សត្របានចេញទៅដល់ ទីបិរគញ្ជ (Birganj ) ទីបញ្ជាការនៃរដ្ឋាភិបាលបណ្ដោះអាសន្នដែលពួកខ្ទាមបានស្ថាបនាឡើង មានរដ្ឋមន្ត្រីនាមមហុន .ស .ជ .ព តនៈ ជាអ្នកមេបញ្ជាការនៃបដិវត្តន៍ ។ សង្គ្រាមក៏ផ្ដើមឡើងនៅទីក្រុងនេះចំពោះកងទាហានខាងព្រះមហាក្សត្រ និងកងទាហានខាងពួកខ្ទាម តែជោគជ័យបានទៅខាងព្រះមហាក្សត្រ ។ សង្គ្រាមនៃទីក្រុងបិរគញ្ជនេះសម្រេចធ្វើឲ្យបដិវត្តន៍ស្ងប់ស្ងាត់ តាំងពីពេលនោះមក ។

(មានត)



## រូបតុក្កតាធ្វើពីទធិជាតិ

តពីលេខ ២ មក

សេចក្តីបំណងតែម្យ៉ាងនៃព្រះនាងទុក្ខកនី ៗ ព្រះមហាក្សត្ររៀបរបនឹងចេញទៅ , ទ្រង់ព្រះតម្រិះនឹកដល់ព្រះនាងទុក្ខកនី ដែលជាអគ្គមហេសីច្បង , ដោយទ្រង់ពុំទាន់បានយាងទៅលា ៗ នៅក្នុងព្រះរាជដំណាក់ទ្រុឌទ្រោមនៃមហេសីទី ១ ដែលព្រះនាងកំពុងផ្តុំលើគំនរនៃសេចក្តីសោយសោក ដោយដណ្តប់កន្ទុះរហែកដូចជាជនអ្នកស្ងូទ្រ: ៗ

ព្រះមហាក្សត្រទ្រង់យាងទៅដល់ក្រឡាបន្ទំទុគតិនៃព្រះនាង; ទ្រង់ពុំបានគង់លើសេយ្យាសន៍របស់ព្រះនាងទេ គ្រាន់តែប្រថាប់ជិតទ្វារបាក់បែកនៃដំណាក់ដ៏គ្រាំគ្រានោះ; ទ្រង់មានព្រះបន្ទូលថា ទុក្ខកនី ! បងរៀបរបនឹងចេញដំណើរទៅទស្សនាភូមិភាគជិតខាង នឹងប្រទេសឆ្ងាយក្នុងពេលឥឡូវនេះហើយ ៗ បងនឹងយកមកឲ្យព្រះនាងប្អូន, នូវខ្សែមាសសម្រាប់ពាក់កដ៏ទន់របស់នាង , កងពណ៌ល្មៀនទុំ សម្រាប់ពាក់ជុំវិញសុរង់ព្រះនាង នុប៉ុះសម្រាប់ពាក់កព្រះបាទានាង ហើយនឹងសំពត់សារីយ៉ាងស្រស់ពណ៌ផ្ទៃមេឃ ដើម្បីជាទីបិទបាំងរាងកាយដ៏បរិសុទ្ធស្អាត របស់ព្រះនាង ដែលមានសម្បុរដូចមាស ៗ ចុះព្រះនាងវិញ, ឲ្យបងយកអ្វីមកឲ្យព្រះនាង ? ចូរព្រះនាងប្រាប់បងតើព្រះនាងប្រាថ្នាវត្ថុអ្វីខ្លះ ?

ព្រះនាងក្រាបទូលព្រះស្វាមីថា: “ ទុកស្តាខ្ញុំព្រះអង្គ ចិត្តប្រាថ្នារបស់ខ្ញុំម្ចាស់ នឹងបានសម្រេចក្នុងពេលដែលព្រះអង្គវិលត្រឡប់ពីទស្សនាការ នៃប្រទេសឆ្ងាយមកកាន់ព្រះរាជអាណាចក្រវិញ ដោយសុវត្ថិភាព ៗ

កាលណាព្រះអង្គស្តេចគង់នៅជិតខ្ញុំម្ចាស់ សេចក្តីស្នេហារបស់ខ្ញុំម្ចាស់ចំពោះព្រះអង្គ នឹងកើតឡើងជាមហាស្ចារ្យ ចំពោះសេចក្តីបំណងរបស់ខ្ញុំម្ចាស់វិញនឹងមានជាអនេក ដូចជាការដែលខ្ញុំម្ចាស់ អាចស្លៀកពាក់សំពត់សារីមាស អុជចង្កៀងមួយពាន់, នៅក្នុងព្រះដំណាក់មានជាន់ប្រាំពីរប្រថាប់នាកណ្តាល នៃពពួកទាសីខ្ញុំម្ចាស់ទាំងប្រាំពីររយ ហើយទ្រទ្រង់នូវវង់មាសនឹងដើងសេកស៊ុកា(១)ដែលទៅក្នុងទ្រុងមាស ៗ

(១) សេក Perruche ) សំណាប់ព្រះមហាក្សត្រ មិនព្រះអគ្គមហេសីច្រើននាក់ទេនឹងរឿងព្រេងនាងទេវធិតានៃប្រទេសឥណ្ឌា ? សេកដែលល្បីល្បាញជាងគេគឺមាននិពន្ធក្នុងរឿងសំស្ក្រឹត “កទម្ពរី” (Ka dambari ) ។សេកនេះជាបុគ្គលិកសំខាន់ក្នុងរឿងនោះ ហើយបានថ្លែងអំពីនិទានគួរ ឲ្យអាណោចអាធម្ម ។



ឱព្រះពជផ្ទួនជីវិតខ្ញុំ បំណាច់ខ្ញុំម្ចាស់ជាច្រើនតែបំណាច់ទាំងនោះ មិនអាចសម្រេចទៅបាន ។ តើខ្ញុំម្ចាស់ត្រូវការគ្រឿងតុបតែងរាងកាយក្នុងសម័យនេះ មានសំពត់សារីមាសត្រើយ, ខ្ញុំម្ចាស់ពាក់ខ្សែរពេជ្រ ឬកងកជង្គង់ក្នុងនាមនៃសេចក្ដីស្នេហាអ្នកណា? ហេតុម្ដេចក៏ខ្ញុំម្ចាស់យកកម្រងផ្កាថ្ងៃទទឹមមកបង់សក់ខ្ញុំម្ចាស់? ឱព្រះមហាក្សត្រថ្លៃវិសេស ថិតកាលទាំងឡាយ កន្លងទៅយូរហើយ ។ ព្រះអង្គអាចយករតនវត្ថុទាំងឡាយមកឲ្យខ្ញុំម្ចាស់ តែសេចក្ដីស្នេហារបស់ព្រះអង្គចំពោះខ្ញុំម្ចាស់ (ជារតនៈដ៏ប្រសើរ) ព្រះអង្គមិនដែលបញ្ចេញ ខ្ញុំម្ចាស់ឃើញជាក់ស្ដែងសោះឡើយ នោះខ្ញុំម្ចាស់មិនអាចមាន ទាស់ប្រាថ្នាពីររយនាក់ឬនៅក្នុងព្រះដំណាក់ឲ្យដាច់បានទេ ។ ព្រះអង្គអាចយកខ្ញុំម្ចាស់ប្រៀបដោយបក្សាក្នុងទ្រុង ដែលជាប់អាស្រ័យក្នុងទ្រុងមាសចុះបើទ្រុងមាសព្រះអង្គមិនអាច ព្រះរាជទានដល់ខ្ញុំម្ចាស់ទេ តើបក្សាព្រៃទឹងពេញចិត្តនៅក្នុងទ្រុងបាក់បែកឬ? បើព្រះអង្គព្រះរាជទានខ្ញុំម្ចាស់ នូវរតនវត្ថុទាំងនោះពោរទីងអ្នកធ្ងន់អាចចូលមកលុកលុយធក់ដណ្ដើម អំពីដំណាក់បាក់បែកនៃខ្ញុំម្ចាស់ដោយងាយ ។ ឱព្រះអង្គគួរឲ្យអនិច្ចាដែរ សូមព្រះអង្គទ្រង់យាងដើម្បីបំពេញនូវបំណងព្រះនាងទេវីដែលទ្រង់សព្វព្រះរាជហឫទ័យចុះ ចំណែកខ្ញុំម្ចាស់នឹងមិនមានបំណងអ្វីឡើយ.....

ព្រះមហាក្សត្រតបទៅព្រះនាងវិញថា ទេនាងមិនគួរនាងត្អូញត្អែរនេះឡើយ ។ បើបងមិនបានយករបស់អ្វីមកឲ្យនាង សមបើគេនិទាបងមិនខាន? តួរនាងប្រាប់នូវបំណងរបស់នាងមក, ព្រះនាងទុក្ខពន្ធីមហេសីបង្គំ ក្រាបទូលព្រះមហាក្សត្រ ជាទីពឹងស្វាមីព្រះអង្គ ខ្ញុំម្ចាស់ សូមក្រាបទូលព្រះអង្គតែមួយម៉ាត់ ខ្ញុំម្ចាស់មានចិត្តខ្មាសអៀនពន់ពេក បើខ្ញុំម្ចាស់មានបំណងទៅលើរតនវត្ថុ ណ្ហើយចុះសូមព្រះអង្គទ្រង់ព្រះមេត្តានាំមកនូវស្វាគូបមួយពីព្រៃមានមុខដូចក្អែកពេលនេះ (១) ព្រះមហាក្សត្រទ្រង់តបទៅព្រះនាងវិញថា ល្អហើយនាង ឥឡូវបងលាដើម្បីធ្វើដំណើរហើយ ព្រះនាងទុក្ខពន់ ទ្រង់សោយសោកាជាខ្លាំងព្រះនាងថ្វាយបង្គំព្រះមហាក្សត្រ ទាំងដលនេត្រស្រស្រាក់ហើយក៏ដួលសន្លប់ទៅលើកន្ទះព្រះនាងទៅ ព្រះមហាក្សត្រចាកចេញហើយយាងត្រះទៅលើខាក់ ។

(១) ពាក្យនេះ ដែលគេពោលចំពោះស្វា ; ហើយបើនឹងខុសៗ មានបំណាច់ណាមួយក ។

ក្នុងសាយណ្ហសម័យព្រះពន្លាកសុវណ្ណជ័យ ត្រដាងក្ដោងមាសត្រាច់តាមសាគរខៀវស្រងាត់ ក្រោមផ្ទៃពពកមានព័ណ៌ដូចមាស កំពុងបណ្ដែតខ្លួននៅលើជលសា នាវាចេះតែឆ្ងាយទៅៗ លុះត្រាផុតចក្ខុនៃសាមញ្ញជន ។

(នៅមានត)

## រឿងជ័យប្រាជ្ញ

តពីលេខ៣មក



ថ្ងៃបុណ្យចូលមកដល់ ហើយរោងល្បាំកុមារជ័យក៏បានបើកនៅពេលនោះដែរ គេឃើញមានលេងល្បាំច្រៀងរាំតាមធម្មតា ឲ្យប្រជាស្ត្រីចូលមើលឥតមានដាក់ក្ដារគន្លឹះទេ ហើយបើកផ្លូវឲ្យចូលបានតាមធម្មតា ។

ថ្ងៃទី ២ បើកលេងល្បាំចាប់ឆាយ ឲ្យតែអ្នកមានទ្រព្យសម្បត្តិចូលមើល គ្មានហេតុអ្វីឡើយ របៀបដូច ថ្ងៃទី ១ ។

ថ្ងៃទី ៣ កុមារជ័យ បានដាក់ឲ្យគេសរសេរដាក់ថា: "ល្បែងពិសេសលេងទម្លាក់ខ្លួនទៅក្នុងរណ្ដៅ ពួកសេវកាមាត្យចូលមើលទទេ មានត្រសារមិនឲ្យចូល ។

ថ្ងៃនេះពពួកមហាជនជាច្រើន នាំគ្នាសុំកុមារជ័យចូលមើលតែគ្រប់គ្នា ដោយស្មានថាជាល្បែងនោះពិសេសអស្ចារ្យ ដែលខ្លួនមិនធ្លាប់ដែលបានឃើញ កុមារជ័យមិនព្រមបើកឲ្យចូលមើលសោះ ។ ជនដែលខះសិទ្ធិចូលមើល តាំងពីខានសិនមានសេចក្ដីស្ដាយដោយមិនបានឃើញល្បែងពិសេស ក្នុងរាត្រីនោះតែគ្រប់គ្នា ដំណឹងនេះនាំឲ្យសាយកាយពាសពេញពជធានី ក្នុងពេលដ៏ខ្លីនោះ ដោយការពោលស្ដាយនៃជនគ្មានសិទ្ធិ ។ គេបាំបានថាដំណឹងនេះនឹងជ្រួតជ្រាបដល់សេវកាមាត្យទាំងឡាយ គ្រប់គ្នាក្នុងពេលដែលកន្លងមកជាពីរ-បី ម៉ោងប៉ុណ្ណោះ; ពួកសេវកាមាត្យទាំងនោះក៏កើតក្នុងចិត្តឥតឧបមា ប្រជុំគ្នាគិតថា យប់នេះមុខជាយើងបានឃើញល្បែងពិសេសមិនខាន ភរិយានឹងបុត្រប្រុស-ស្រីរបស់អាមាត្យទាំងនោះ ចេះតែរំអុកចង់ទៅមើលជាមួយផង តែមិនសម្រេចដូចបំណងព្រោះមានបំរាមហាម "អ្នកមានត្រសារមិនឲ្យចូល" ។

លុះដល់ពេលព្រលប់ពួកក្មេងនឹងអ្នកកំបានមកជួបជុំចូលទៅកាន់ទីលេងតាមធម្មតា ៗសំឡេងតូរ្យតន្ត្រីនឹងសំឡេងច្រៀងបណ្ដែតតាមសន្ធាក់ព្យួលាន់ឡើង

យ៉ាងពិរោះ គួរឲ្យរំភើបចិត្ត ។ កុមារជ័យ បានសរសេរ ផ្លាក ១ ទៀតមានសេចក្តីថា "សូមអញ្ជើញចូលម្នាក់ម្តងជាលំដាប់លំដោយគ្នា" ។

ពួកសេនាមាត្យទាំងឡាយ បានតែងខ្លួនស្អាតបាត ដោយសំលៀកបំពាក់យ៉ាងឆើតឆាយ ចេញចាកគេហស្ថានរៀងខ្លួន ដើរមកដោយមានកិរិយាហឹហា ទឹងដោយបុកពោយ៉ាងក្រអឺតក្រអប់ ។ គ្នា ឆ្ពោះមកកាន់រោងល្បាំនោះ លុះដល់ឃើញអក្សរនៅបន្ទះក្តារដាក់ថា "ឲ្យចូលម្នាក់ម្តង ៗ" ក៏ចូលទៅតាមរបៀបនោះ ។ អ្នកដើរចូលទៅមុនលុះចូលទៅជាន់ត្រង់ក្តារគន្លឹះនោះ ស្រាប់តែបាស់ធ្លាក់ខ្លួនត្រឹសទៅក្នុងរណ្តៅលិតឈឹង; អ្នកបន្ទាប់មកក៏ជាន់បាស់ធ្លាក់ត្រឹសបន្ត ៗ គ្នា ។ កុមារជ័យនៅចាំមាត់ទ្វារ កាលបើអាមាត្យម្នាក់ធ្លាក់បាត់ទៅហើយ ទើបបើកឲ្យម្នាក់ចូលទៅទៀត ៗ អាមាត្យទាំងឡាយចេះតែចូលបន្តៗគ្នាហើយធ្លាក់ទៅក្នុងរណ្តៅត្រឹសៗ បន្ត ៗ គ្នាជាលំដាប់ ។

ទីនោះងងិតឈឹងគ្មានពន្លឺភ្លើងចាំងចូលទៅដល់បន្តិចបន្តួចសោះឡើយម្នាក់ធ្លាក់ទៅហើយ ម្នាក់ធ្លាក់ទៅទៀតរាសដៃ រាសជើងទៅប៉ះគ្នា អ្នកសួរចេះតែសួរថា "នរណានេះ" អ្នកឆ្លើយចេះឆ្លើយថា "អញៗ" លុះប៉ះចុះប៉ះឡើងអ្នកដដែល ៗ សួរ-ឆ្លើយ ៗ ទៅវិញទៅមកថា "នរណា-អញ" ដដែល ៗ ។ បើទុកជាស្គាល់មាត់ម្នាក់ហើយ តែកាលណាប៉ះគ្នាទៅទៀតក៏សួរគ្នាទៀតដដែល ៗ រវល់តែប៉ះគ្នាឆាកទៅឯណោះអញឆាកមកឯណោះអញ ស្ទាបពពឹមពពើម រកផ្លូវចេញច្រលំច្របល់ត្រឡប់ត្រឡិនក្នុងរណ្តៅ ។ អ្នកធ្លាក់ក៏ចេះតែធ្លាក់បន្តគ្នាបន្តិចត្រឹស ៗ ម្នាក់ម្តងៗ ។ អ្នកមុនស្ទាបរកផ្លូវចេញបានដល់ជណ្តើរហើយ ប្រឹងប្រវេប្រវាឡើង យកក្បាលទូលបន្ទះក្តារហើយចេញមកធ្វើមុខស្រមេះ ។

អ្នកនៅខាងក្រៅ ឃើញ អ្នកទាំងនោះ ចេញមកហើយ សួរថាមេចទៅ រាំល្អមើលគ្រាន់បើទេ ។

អ្នកចេញមកទាំងនោះ ខ្លះក៏លើកដៃទាំងពីរឡើងត្រីក្បាលបញ្ចេញសំឡេងដោយក្បិតមាត់ថា ហ៊ឹ ៗ ; ពីរបីដងហើយដើរចេញទៅ អ្នកខ្លះមុខឡើងក្រហមស្ទើរស្រក់ឈាម គ្រាន់តែគ្រវីក្បាលហើយដើរចេញទៅ, អ្នកខ្លះមានទឹកមុខស្រងូតចេញទៅដោយស្ងៀមស្ងាត់ អ្នកខ្លះទឹកអស់សំណើចគ្រវីក្បាលហើយលាន់មាត់ថា នេះហៅចំជាអស្ចារ្យ! តាំងពីកើតមកមិនដែលជួបប្រទះសោះៗ

អ្នកនៅក្រៅឃើញអាការៈយ៉ាងនេះ នឹកស្មានថា ល្បែងពិសេសនេះមិនដឹងជាល្អមើលយ៉ាងណាទេ មើលទៅ; បានជាអ្នកអស់នេះ ចេញមកមានអាការៈគួរឲ្យអស្ចារ្យក្នុងចិត្តដូច្នេះ ម្ល៉ោះហើយចេះតែនាំគ្នាចូលទៅ ធ្លាក់ក្នុងរណ្តៅពាល់តែអស់ ។

មហាជនដែលនៅចោមរោមជុំវិញរោង នោះ

(នៅមានត)

* * *



កាលពីថ្ងៃទី ២៦ មីនា ១៩៥៤ ព្រះតេជគុណព្រះពោធិវង្ស ចាងហ្វាងសាលាបាលីជាន់ខ្ពស់ ជាមួយនឹងព្រះគ្រូធម៌វរៈត្រៃពុទ្ធិកសមាគមនឹងរាជរដ្ឋាភិបាល ចាត់ឲ្យនិមន្តទៅធ្វើសន្និសីទជាមួយនឹងក្រុមសទ្ធិ-ជន នាក្រុងតូក្យូប្រទេសជប៉ុន តាមលិខិតអញ្ជើញនៃក្រុមនោះ ។

ដល់ថ្ងៃទី ១៤ ឧសភា ១៩៥៤ លោកបានត្រឡប់មកកាន់ប្រទេសកម្ពុជាវិញ ។

ប្រទេសកម្ពុជា

ភ្ជាប់កាន់ព្រះពុទ្ធសាសនាមកជាង ១ ពាន់ឆ្នាំហើយ មានបព្វជិតសិក្សាវិជ្ជាផ្លូវសាសនាជាច្រើន

កាលសម័យអង្គរ មានកើតវិទ្យាល័យពុទ្ធ-សមនា នៅនគរវត្ត; ដល់មកសម័យរាជ-ធានីភ្នំពេញមានកើតវិទ្យាល័យ ពុទ្ធសាសនា នៅភ្នំពេញ មានសាស្ត្រាចារ្យជាបព្វជិត និងគ្រហស្ថបម្រុះគ្នា តែចាងហ្វាងនៃវិទ្យាល័យនេះ ជាបព្វជិត មាននាមថាព្រះតេជ-គុណព្រះពោធិវង្ស ហួត-តាត ដែលកាន់កាប់សព្វថ្ងៃនេះ មានសិស្សចំនួនជា ៤០០ អង្គកំពុងសិក្សាសព្វថ្ងៃ

ឥឡូវនេះ ប្រទេសកម្ពុជាកំពុងកសាងមហាវិទ្យាល័យខាងព្រះពុទ្ធសាសនា ១ ទៀត ឲ្យឈ្មោះថាមហាវិទ្យាល័យព្រះសីហនុរាជ្យ ។

